# ប្រកាសស្តីពីនីតិវិធីនៃការផ្ញើនៅតុលាការ


**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** · · · · · · · · · · · · · · · · · · · ៥

**ប្រការ ១**.- គោលបំណង · · · · · · · · · · · · · · · · · · · · ៥

**ប្រការ ២**.- មន្ត្រីទទួលបន្ទុកកិច្ចការផ្ញើ · · · · · · · · · · · · · · · ៦

**ប្រការ ៣**.- ការចាត់ចែងរបស់ក្រឡាបញ្ជីចំពោះកិច្ចការផ្ញើ · · · · · · · · ៧

**ប្រការ ៤**.- សមត្ថកិច្ចលើការផ្ញើសម្រាប់ជាប្រាតិភោគលើបណ្តឹង · · · · · · · ៩

**ប្រការ ៥**.- ការប្រគល់នូវច្បាប់ដើមនៃឯកសារភ្ជាប់ · · · · · · · · · · · ១២

**ជំពូកទី ២ នីតិវិធីផ្ញើវត្ថុដែលជាកម្មវត្ថុនៃការផ្ញើ** · · · · · · · · · · · ១៤

**ប្រការ ៦**.- ពាក្យសុំផ្ញើ · · · · · · · · · · · · · · · · · · · · · ១៤

**ប្រការ ៧**.- ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំផ្ញើ · · · · · · · · · ១៧

**ប្រការ ៨**.- ការផ្ញើឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះ · · · · · ១៨

**ប្រការ ៩**.- ការផ្ញើដើម្បីការប្តូរប្រាតិភោគ · · · · · · · · · · · · · · ១៨

**ប្រការ ១០**.-នីតិវិធីទទួលពាក្យសុំផ្ញើ · · · · · · · · · · · · · · · · ២១

**ប្រការ ១១**.- បញ្ញត្តិពិសេសអំពីការទទួលប្រាក់ផ្ញើ · · · · · · · · · · · ២២

**ប្រការ ១២**.-ការលើកចោលនូវពាក្យសុំផ្ញើ · · · · · · · · · · · · · · · ២៥

**ជំពូកទី ៣ នីតិវិធីប្រគល់នូវវត្ថុផ្ញើ** · · · · · · · · · · · · · · · · ២៧

**ប្រការ ១៣**.-ការប្រគល់ឱ្យនូវវត្ថុផ្ញើ · · · · · · · · · · · · · · · · ២៧

**ប្រការ ១៤**.-ការប្រគល់វិញនូវវត្ថុផ្ញើ · · · · · · · · · · · · · · · · ២៨

**ប្រការ ១៥**.-ការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ · · · · · · · · · · · · · · ២៩

**ប្រការ ១៦**.-ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ជាអាទិ៍ ៣១

**ប្រការ ១៧**.-ការអនុញ្ញាតឱ្យប្រគល់នូវវត្ថុផ្ញើ · · · · · · · · · · · · · ៣៤

**ប្រការ ១៨**.-ការសរសេរនៅក្នុងលិខិតពាក្យសុំសម្រាប់តុលាការ ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើ · · · · · · · · · · · · · · · · · · · · · ៣៤

**ប្រការ ១៩**.- ការលើកចោលនូវការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ · · · · · · · ៣៥

**ជំពូកទី ៤ បញ្ញត្តិផ្សេងៗ** · · · · · · · · · · · · · · · · · · · · ៣៦

**ប្រការ ២០**.-ការមើលឯកសារដែលទាក់ទងនឹងការផ្ញើ · · · · · · · · · · ៣៦

**ប្រការ ២១**.-ការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើ · · · · · · · · ៣៦

**ជំពូកទី ៥ អវសានប្បញ្ញត្តិ** . . . . . . . . . . . . . . . . . . ៣៧
**ប្រការ ២២**.-កាលបរិច្ឆេទនៃការអនុវត្ត . . . . . . . . . . . . . . . . . ៣៧

**ឧបសម្ព័ន្ធ**

ទម្រង់លេខ ១: លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន)

ទម្រង់លេខ ២: លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន)

ទម្រង់លេខ ៣ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ )

ទម្រង់លេខ ៤ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ)

ទម្រង់លេខ ៥ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

ទម្រង់លេខ ៦ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

ទម្រង់លេខ ៧ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ៨ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ ដើម្បីធានាតាមផ្លូវ តុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ៩ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ១០ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត) (ការបង់តាមវិធីផ្ទេរប្រាក់)

ទម្រង់លេខ ១១ : លិខិតជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ

ទម្រង់លេខ ១២ : លិខិតស្នើសុំផ្ទេរប្រាក់

ទម្រង់លេខ ១៣ : លិខិតទាមទារឱ្យប្រគល់នូវប្រាក់ផ្ញើ

ទម្រង់លេខ ១៤ : លិខិតទាមទារឱ្យប្រគល់នូវឧបករណ៍អាចជួញដូរបានដែលបានផ្ញើ (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ)

ទម្រង់លេខ ១៥ : លិខិតពាក្យសុំឱ្យមើលឯកសារ

ទម្រង់លេខ ១៦ : លិខិតពាក្យសុំឱ្យធ្វើការបញ្ជាក់

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះបញ្ញត្តអំពីនីតិវិធីនៃការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន នៅតុលាការ ដោយផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី ។

(កំណត់)

ប្រការនេះចែងថា ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធីនៃការផ្ញើនៅតុលាការ ដោយផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី ដែលជានីតិវិធីចាំបាច់សម្រាប់អនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី ។

ប្រការនេះកំណត់អំពីកម្មវត្ថុនៃការផ្ញើ ជា "ប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ" ។ ការចែងបែបនេះ មានមូលហេតុថា មាត្រា ៧១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាបញ្ញត្តិមូលដ្ឋាននៃការផ្ញើដើម្បីដាក់ប្រាតិភោគលើបណ្ដឹង ចែងថា "វិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ" គឺជាវិធីមួយនៃការដាក់ប្រាតិភោគ ។

ឧបករណ៍អាចជួញដូរបានដែលអាចត្រូវបានផ្ញើ មានការកម្រិតតែ "ឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ " ប៉ុណ្ណោះ ។ ក្នុងករណីផ្ញើប្រាក់ ប្រាក់នេះអាចយកទៅសងសិទ្ធិលើបំណុលដែលត្រូវបានធានាដោយភ្លាមបាន ប៉ុន្តែ ក្នុងករណីផ្ញើឧបករណ៍អាចជួញដូរបានវិញ មានភាពចាំបាច់ប្ដូរជាប្រាក់ ដើម្បីយកទៅសងសិទ្ធិលើបំណុលដែលត្រូវបានធានា ហើយចំពោះការប្ដូរជាប្រាក់នេះ មានបញ្ហាអំពីភាពប្រាកដ ភាពងាយស្រួល និង ការប្រែប្រួលតម្លៃ ជាដើម ។ ហេតុដូច្នេះ ច្បាប់តម្រូវឱ្យតុលាការវិនិច្ឆ័យអំពីភាពសមរម្យក្នុងការយកជាកម្មវត្ថុនៃប្រាតិភោគ ដើម្បីជៀសវាងការខូចខាតផលប្រយោជន៍របស់ជនដែលមានសិទ្ធិប្រាតិភោគ និង ដើម្បីឱ្យមានប្រយោជន៍ដូចគ្នានឹងករណីផ្ញើប្រាក់ ។

ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវភាពសមរម្យនៃឧបករណ៍អាចជួញដូរបាននីមួយៗ អាស្រ័យលើការវិនិច្ឆ័យដោយឆន្ទានុសិទ្ធិរបស់តុលាការ ប៉ុន្តែ ដើម្បីវិនិច្ឆ័យអំពីភាពសមរម្យនោះ តុលាការគប្បីគិតពិចារណាអំពីចំណុចដូចជា (១) ភាពប្រាកដក្នុងការប្ដូរជាប្រាក់ (តើមានការបារម្ភថា ស្ថាប័នដែលចេញឧបករណ៍នោះ អាចក្លាយទៅជាភាពអសាធនីយ ?) (២) ភាពងាយស្រួលក្នុងការប្ដូរជាប្រាក់ នៅក្នុងផ្សារសាធារណៈ ជាដើម (៣) ស្ថិរភាពនៃតម្លៃ ជាដើម ដោយទូលំទូលាយ ។ តាមការជាក់ស្ដែង ចំពោះប័ណ្ណបំណុលសាធារណៈ ដូចជាប័ណ្ណបំណុលរដ្ឋ និង ប័ណ្ណអាជ្ញាធររដ្ឋបាលខេត្ត ជាដើម តុលាការអាចទទួលស្គាល់ថាសមរម្យបាន រីឯចំពោះ

ភាគហ៊ុនរបស់សហគ្រាសឯកជន ជាដើម ដែលអាចមានការប្រែប្រួលនូវតម្លៃ តាមការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច តុលាការគួរតែគិតពិចារណាអំពីភាពសមរម្យនោះ ដោយហ្មត់ចត់ និង ដោយប្រុងប្រយ័ត្ន ។ ម្យ៉ាងទៀត ក្រឡាបញ្ជីដែលទទួលបន្ទុកកិច្ចការផ្ញើ គ្មានសិទ្ធិវិនិច្ឆ័យអំពីភាពសមរម្យនោះ ហេតុដូច្នេះ ក្រឡាបញ្ជីមិនអាចលើកចោលពាក្យសុំផ្ញើ ដោយយកភាពគ្មានសមរម្យមកជាមូលហេតុឡើយ ។

## ប្រការ ២.- មន្ត្រីទទួលបន្ទុកកិច្ចការផ្ញើ

កិច្ចការផ្ញើនៅតុលាការ ត្រូវបំពេញដោយក្រឡាបញ្ជីដែលត្រូវបានចាត់តាំងដោយប្រធានតុលាការនៃតុលាការដែលត្រូវទទួលការផ្ញើនោះ ។

(កំណត់)

១. ប្រការនេះមានចែងថា កិច្ចការផ្ញើនៅតុលាការត្រូវធ្វើឡើងដោយក្រឡាបញ្ជីនៃតុលាការដែលទទួលការផ្ញើ ។
២. "ក្រឡាបញ្ជីនៃតុលាការដែលត្រូវទទួលការផ្ញើ" សំដៅលើក្រឡាបញ្ជីដែលស្ថិតនៅក្រោមស្ថាប័នតុលាការដែលតុលាការក្នុងនាមជាអង្គវិនិច្ឆ័យដែលទទួលការផ្ញើនោះស្ថិតនៅ ។ មានន័យថា ក្រឡាបញ្ជីនេះមិនចាំបាច់ត្រូវតែជាក្រឡាបញ្ជីនៃតុលាការ (ក្នុងន័យអង្គវិនិច្ឆ័យ) ដែលបង្គាប់ឱ្យដាក់ប្រាតិភោគ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៦៧ កថាខណ្ឌទី ១ ជាអាទិ៍) ឬ នៃតុលាការអនុវត្ត ឬ នៃតុលាការអនុវត្តការរក្សាការពារទេ គឺគ្រាន់តែជាក្រឡាបញ្ជីដែលបម្រើការងារនៅតុលាការដែលជាស្ថាប័នរដ្ឋដែលអង្គវិនិច្ឆ័យនោះស្ថិតនៅបានហើយ ។
៣. ក្រឡាបញ្ជីដែលបំពេញកិច្ចការផ្ញើនេះ គឺជាអ្នកចាត់ចែងកិច្ចការពាក់ព័ន្ធនឹងសាច់ប្រាក់ និង ឧបករណ៍អាចជួញដូរបាន ដែលមានចំនួនច្រើន ព្រមទាំងត្រូវមានចំណេះជំនាញស្តីពីការផ្ញើនេះផង ដូច្នេះហើយ ប្រការនេះបញ្ញត្តថា ក្នុងចំណោមក្រឡាបញ្ជីទាំងអស់ដែលស្ថិតនៅក្រោមស្ថាប័នតុលាការ មានតែក្រឡាបញ្ជីមួយចំនួនដែលត្រូវបានចាត់តាំងដោយប្រធានតុលាការទេ ទើបអាចប្រតិបត្តិកិច្ចការផ្ញើនេះបាន ។ មានវិធីបញ្ញត្តមួយទៀតដើម្បីឱ្យក្រឡាបញ្ជីជាក់លាក់ណាបំពេញកិច្ចការផ្ញើ គឺការបញ្ញត្តក្នុងប្រកាសនេះដោយគ្រាន់តែសរសេរថា "ក្រឡាបញ្ជីនៃតុលាការដែលត្រូវទទួលការផ្ញើ" ប៉ុណ្ណោះ ហើយទុកឱ្យវិធីបែងចែកការងារ ឬ វិធានផ្ទៃក្នុងផ្សេងទៀតកំណត់អំពីក្រឡាបញ្ជីដែលទទួលបន្ទុកកិច្ចការផ្ញើ ។ ក៏ប៉ុន្តែ ជាការប្រសើរ ត្រូវចែងនៅក្នុងប្រកាសនេះឱ្យស្រេច ពីព្រោះចាំបាច់ត្រូវកំណត់ឱ្យច្បាស់អំពីអ្នកដែលត្រូវទទួលខុសត្រូវ ក្នុងការបំពេញកិច្ចការពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ។ នៅក្នុងប្រទេសជប៉ុន មាត្រា ២ នៃច្បាប់ស្តីពីការតម្កល់របស់ជប៉ុនចែងថា អ្នកបំពេញកិច្ចការតម្កល់ គឺជាមន្ត្រីរដ្ឋបាលច្បាប់ ដែលកំពុងបម្រើការងារនៅមន្ទីរកិច្ចការច្បាប់ ឬ មន្ទីរកិច្ចការច្បាប់ប្រចាំខេត្ត ហើយដែលត្រូវបានចាត់តាំងដោយប្រធានមន្ទីរកិច្ចការច្បាប់ ឬ មន្ទីរកិច្ចការច្បាប់ប្រចាំខេត្តនោះ ។

**ប្រការ ៣.-** ការចាត់ចែងរបស់ក្រឡាបញ្ជីចំពោះកិច្ចការធ្វើ

១-ការចាត់ចែងរបស់ក្រឡាបញ្ជីទាក់ទងនឹងកិច្ចការធ្វើ នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹងតាមរបៀបដែលអាចចាត់ទុកថាសមរម្យ ។

២-ពាក្យសុំតវ៉ាអំពីការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវដាក់ជាលាយល័ក្ខណ៍អក្សរ ទៅតុលាការដែលក្រឡាបញ្ជីដែលបានធ្វើការចាត់ចែងនោះស្ថិតនៅក្រោម ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ក្រោយពីបានទទួលដំណឹងនោះ ។

៣-អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនអាចពន្យារបានឡើយ ។

៤-ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៥-ចំពោះបណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ត្រូវអនុលោមទៅតាមបណ្តឹងជំទាស់ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

(កំណត់)

១. ប្រការនេះចែងអំពីពេលដែលការចាត់ចែងរបស់ក្រឡាបញ្ជីចំពោះការធ្វើត្រូវបង្កើតអានុភាព និង ចែងអំពីឧបាស្រ័យចំពោះការចាត់ចែងរបស់ក្រឡាបញ្ជី ។

កិច្ចការធ្វើនៅតុលាការ មិនមែនមានត្រឹមតែកិច្ចការថែរក្សាទុកនូវវត្ថុដែលត្រូវបានដាក់ធ្វើដែលជាសកម្មភាពជាក់ស្តែងប៉ុណ្ណោះទេ ប៉ុន្តែ វារាប់បញ្ចូលទាំងការវិនិច្ឆ័យថា តើត្រូវទទួលពាក្យសុំធ្វើដែរឬយ៉ាងណា និង តើត្រូវអនុញ្ញាតឱ្យប្រគល់នូវវត្ថុដែលត្រូវបានធ្វើ តាមការទាមទារដែរឬទេ ផងដែរ ។ ការសម្រេចសេចក្តីទាំងនោះត្រូវធ្វើឡើងក្នុងរូបភាពជាការចាត់ចែងរបស់ក្រឡាបញ្ជី ហេតុដូច្នេះ ចាំបាច់ត្រូវតែបញ្ជាក់អំពីពេលដែលការចាត់ចែងនោះបង្កើតអានុភាព និង របៀបឧបាស្រ័យចំពោះការចាត់ចែងនោះ ។

អាស្រ័យហេតុនេះ ប្រការនេះចែងថា ការចាត់ចែងរបស់ក្រឡាបញ្ជី នឹងមានអានុភាព បន្ទាប់ពីបានជូនដំណឹងតាមរបៀបដែលអាចចាត់ទុកថាសមរម្យ ដូចការចាត់ចែងរបស់ក្រឡាបញ្ជីក្នុងនីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី (កថាខណ្ឌទី ១ មាត្រា ៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយកំណត់អំពីការតវ៉ាចំពោះការចាត់ចែងនោះ និង វិធីឧបាស្រ័យផ្សេងទៀត ។

២. ការចាត់ចែងរបស់ក្រឡាបញ្ជីចំពោះការផ្ញើនៅតុលាការ នឹងមានអានុភាពបន្ទាប់ពីបានជូនដំណឹងតាមរបៀបដែលអាចចាត់ទុកថាសមរម្យ (កថាខណ្ឌទី ១) ។ មានន័យថាមិនចាំបាច់ត្រូវតែធ្វើការបញ្ជូនដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ២ ជំពូកទី ៨ ផ្នែកទី ២ ទេ ។

៣. ចំពោះការចាត់ចែងរបស់ក្រឡាបញ្ជី អាចធ្វើឧបាស្រ័យបាន ដោយការដាក់ពាក្យសុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅក្រោម (កថាខណ្ឌទី ២) ។

ក្រឡាបញ្ជីដែលបំពេញកិច្ចការផ្ញើ មិនចាំបាច់ត្រូវតែជាក្រឡាបញ្ជីនៃតុលាការ (ក្នុងន័យអង្គវិនិច្ឆ័យ) ដែលទទួលពាក្យបណ្ដឹង ឬ តុលាការអនុវត្តទេ គឺគ្រាន់តែជាក្រឡាបញ្ជីដែលបម្រើការងារនៅស្ថាប័នតុលាការទៅបានហើយ (សូមមើលកំណត់ទី ២ នៃមាត្រា ២) ។ ហេតុដូច្នេះ "តុលាការដែលក្រឡាបញ្ជីដែលបានធ្វើការចាត់ចែងនោះស្ថិតនៅក្រោម" នៅក្នុងកថាខណ្ឌទី ២ នៃប្រការនេះ ក៏មិនចាំបាច់ត្រូវតែជាតុលាការ (ក្នុងន័យអង្គវិនិច្ឆ័យ) ដែលទទួលពាក្យបណ្ដឹង ឬ តុលាការអនុវត្តទេ គឺគ្រាន់តែជាអង្គវិនិច្ឆ័យដែលស្ថិតនៅស្ថាប័នតុលាការដែលក្រឡាបញ្ជីនោះបំពេញកិច្ចការទៅបានហើយ ។ ឯបញ្ហាថាតើ អង្គវិនិច្ឆ័យ (ចៅក្រម) ណាមួយដែលត្រូវទទួលបន្ទុកវិនិច្ឆ័យអំពីពាក្យសុំតវ៉ា គឺត្រូវកំណត់ដោយវិធានបែងចែកការងាររបស់តុលាការនោះទៅ ។

៤. អំឡុងពេលសម្រាប់ដាក់ពាក្យបណ្ដឹងតវ៉ាគឺ ១ សប្ដាហ៍ (កថាខណ្ឌទី ២) ។

តាមច្បាប់ស្ដីពីការតម្កល់របស់ជប៉ុន ការចាត់ចាត់ចែងរបស់មន្ត្រីបំពេញកិច្ចការផ្ញើ ជាការចាត់ចែងផ្នែករដ្ឋបាល ហើយឧបាស្រ័យចំពោះការចាត់ចែងការផ្ញើ ត្រូវធ្វើឡើងជាបណ្ដឹងមួយប្រភេទជាកំណត់តាមច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីផ្នែករដ្ឋបាល ។ ជាគោលការណ៍ អំឡុងពេលសម្រាប់ដាក់ពាក្យបណ្ដឹងគឺ ៦ ខែ គិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីការចាត់ចែងនោះ ។ រីឯប្រកាសស្ដីពីការផ្ញើនៅតុលាការរបស់កម្ពុជាវិញបញ្ញត្តថា ការចាត់ចែងកិច្ចការផ្ញើនេះ មិនមែនជាការចាត់ចែងផ្នែករដ្ឋបាលទេ គឺជាការចាត់ចែងរបស់ក្រឡាបញ្ជីដែលជាសមាសភាពនៃអំណាចតុលាការ ។ នៅប្រទេសជប៉ុន ករណីតម្កល់ភាគច្រើនមិនស្ថិតនៅក្នុងប្រភេទនៃការតម្កល់ដែលតម្រូវឱ្យមានវិវាទជាក់ស្ដែងជាល័ក្ខខ័ណ្ឌនៃការតម្កល់ ដូចជាការតម្កល់សម្រាប់ការសង ជាដើម រីឯការផ្ញើក្នុងប្រកាសស្ដីពីការផ្ញើនៅតុលាការនេះ ត្រូវបានរៀបចំឡើងជានីតិវិធីបន្ទាប់បន្សំចំពោះនីតិវិធីជំនុំជម្រះ ការអនុវត្តដោយបង្ខំ និងការរក្សាការពារ ក្នុងរឿងរដ្ឋប្បវេណី ដែលជាផ្នែកមួយនៃបណ្ដានីតិវិធីសម្រាប់ដោះស្រាយវិវាទ ហើយទាមទារឱ្យមាននូវចំណាត់ការឆាប់រហ័សមួយ ។ ដោយហេតុនេះ យើងបានកំណត់រយៈពេល ១ សប្ដាហ៍ ជាអំឡុងពេលសម្រាប់ដាក់ពាក្យសុំតវ៉ា ដូចគ្នាទៅនឹងអំឡុងពេលសម្រាប់ធ្វើបណ្ដឹងជំទាស់ដែរ ។

៥. ក្នុងនីតិវិធីនៃការផ្ញើនៅតុលាការ ការដាក់ពាក្យសុំផ្ញើ និង ការទាមទារឱ្យប្រគល់ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ហេតុដូច្នេះ ប្រការនេះចែងថា ពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់ក្រឡាបញ្ជី ក៏ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរដែរ (កថាខណ្ឌទី ២) ។

៦. ទោះបីជាក្នុងកាលៈទេសៈដែលមិនអាចជៀសរួចក៏ដោយ ក៏អំឡុងពេលសម្រាប់ធ្វើការតវ៉ានេះមិនអាចពន្យារបានឡើយ (កថាខណ្ឌទី ៣) ។ មូលហេតុដែលមិនអនុញ្ញាតឱ្យពន្យារពេល គឺដោយសារតែហេតុថា អំឡុងពេលនៃការតវ៉ាត្រូវតែកំណត់ដូចគ្នា ដោយមិនគិតពីស្ថានភាពនៃករណីនីមួយៗទេ ហើយការអនុញ្ញាតឱ្យពន្យារពេលដោយយោងទៅតាមស្ថានភាពនៃករណីនីមួយៗនោះ ក៏មិនសមរម្យដែរ ។

៧. ការសម្រេចសេចក្តីអំពីពាក្យសុំតវ៉ា ត្រូវធ្វើដោយដីកាសម្រេចរបស់តុលាការ ។

ដីកាសម្រេចអំពីពាក្យសុំបណ្តឹងតវ៉ាចំពោះការចាត់ចែងរបស់ក្រឡាបញ្ជីក្នុងកិច្ចការផ្ញើ អាចប្តឹងជំទាស់បាន (កថាខណ្ឌទី ៤) ។

## ប្រការ ៩.- សមត្ថកិច្ចលើការផ្ញើសម្រាប់ជាប្រាតិភោគលើបណ្តឹង

ការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន នៅតុលាការ ដែលជាវិធីដាក់ប្រាតិភោគ ដោយយោងតាមបញ្ញត្តិពីគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) ដល់គន្ថីទី ៥ (នីតិវិធីដាស់តឿន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវធ្វើឡើងនៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគនោះ ។

(កំណត់)

១. ប្រការនេះកំណត់ពីសមត្ថកិច្ចរបស់តុលាការលើការផ្ញើនៅតុលាការ ចំពោះការផ្ញើនៅតុលាការដែលគ្មានបញ្ញត្តិអំពីសមត្ថកិច្ចរបស់តុលាការ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងចំណោមការផ្ញើដែលធ្វើឡើងដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

ជាគោលការណ៍ បញ្ញត្តិនីមួយៗដែលជាមូលដ្ឋាននៃការផ្ញើ មានកំណត់អំពីសមត្ថកិច្ចទៅតាមដែនដី គឺសំដៅលើន័យថា ការផ្ញើត្រូវធ្វើទៅតុលាការណា ហើយតុលាការដែលបានកំណត់នៅក្នុងបញ្ញត្តិនីមួយៗនោះ ត្រូវក្លាយជាតុលាការដែលមានសមត្ថកិច្ចលើការផ្ញើ ។ ហេតុដូច្នេះ ប្រកាសស្តីពីការផ្ញើនៅតុលាការនេះមិនចាំបាច់កំណត់អំពីសមត្ថកិច្ចទៅតាមដែនដីឡើយ ។

ចំពោះការផ្ញើសម្រាប់ជាប្រាតិភោគដោយផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីវិធីដាក់ប្រាតិភោគ ដែលមានដូចជា ①វិធីតម្កល់ជាប្រាក់ ឬ ជាឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ នៅកន្លែងតម្កល់ ②វិធីផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលតុលាការទទួលស្គាល់ថាសមរម្យ នៅតុលាការ ③វិធីដែលបានកំណត់ផ្សេង ។ ក៏ប៉ុន្តែ ចំពោះវិធីផ្ញើនៅតុលាការ ពុំមានបញ្ញត្តិណាមួយកំណត់អំពីតុលាការដែលត្រូវទទួលការផ្ញើច្បាស់លាស់ទេ ។ ដូច្នេះ ចាំបាច់ត្រូវ

កំណត់នៅក្នុងប្រកាសនេះអំពីសមត្ថកិច្ចតុលាការ ចំពោះប្រភេទនៃការផ្ញើដែលមិនទាន់មានបញ្ញត្តិណាមួយកំណត់អំពីសមត្ថកិច្ចនៅឡើយ ។ ហេតុនេះហើយ ប្រការនេះចែងស្តីពីសមត្ថកិច្ចលើការផ្ញើសម្រាប់ប្រាតិភោគតាមក្រមនីតិវិធីរដ្ឋប្បវេណី ក្រៅពីការផ្ញើសម្រាប់ប្រាតិភោគតាមគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) និង គន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានបញ្ញត្តិស្តីពីសមត្ថកិច្ច (សូមមើលចំណុចលេខ ២ ខាងក្រោមនេះ) ដោយមានខ្លឹមសារដូចគ្នានឹងការផ្ញើសម្រាប់ប្រាតិភោគតាមគន្ថីទី ៦ និង គន្ថីទី ៧ នោះ ។

២. ក្រមនីតិវិធីរដ្ឋប្បវេណីផ្តល់នូវបញ្ញត្តិជាច្រើនស្តីពីសមត្ថកិច្ចតាមដែនដីចំពោះការផ្ញើនៅតុលាការដែលធ្វើឡើងដោយផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានដូចជា :

ការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន សម្រាប់ការដាក់ប្រាតិភោគលើបណ្តឹង (មាត្រា ៧១) :

តុលាការ ដែលបង្គាប់ឱ្យដាក់ប្រាតិភោគ (ប្រការ ៤ នៃប្រកាសនេះ) ។

ការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន សម្រាប់ការដាក់ប្រាតិភោគ តាមបញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) (មាត្រា ៣៧៧) :

តុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ ឬ តុលាការអនុវត្ត (មាត្រាដដែល) ។

ការផ្ញើប្រាក់ដែលបានមកពីការលក់ ក្នុងករណីដែលអាជ្ញាសាលាបានលក់នូវចលនវត្ថុដែលត្រូវបានរឹបអូស ក្នុងពេលដែលការអនុវត្តដោយបង្ខំចំពោះចលនវត្ថុកំពុងត្រូវបានផ្អាក (មាត្រា ៣៩៧ កថាខណ្ឌទី ២) :

សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ (កថាខណ្ឌដដែល) ។

ការផ្ញើទុកនូវទឹកប្រាក់ស្មើនឹងចំណែករបស់ម្ចាស់បំណុលដែលត្រូវទុក ក្នុងករណីដែលអាជ្ញាសាលាអនុវត្តការចែកចំណែក ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (មាត្រា ៤០០ កថាខណ្ឌទី ១) :

សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ (កថាខណ្ឌដដែលនេះ) ។

ការផ្ញើទុកនូវទឹកប្រាក់ស្មើនឹងចំណែករបស់ម្ចាស់បំណុលដែលមិនបានបង្ហាញខ្លួនដើម្បីទទួលចំណែក នៅកាលបរិច្ឆេទចែកចំណែក ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (មាត្រា ៤០០ កថាខណ្ឌទី ២) :

សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ (កថាខណ្ឌដដែល) ។

ការផ្ញើដោយកូនបំណុលទី ៣ ក្នុងករណីដែលសិទ្ធិលើបំណុលដែលមានបំណងឱ្យសងជាប្រាក់ត្រូវបានរឹបអូស (លើកលែងតែការរឹបអូសសិទ្ធិលើបំណុលនេះ ត្រួតគ្នា) (មាត្រា ៤១១ កថាខណ្ឌទី ១, ដែលហៅថា "ការផ្ញើដោយមានសិទ្ធិ") :

តុលាការអនុវត្ត (កថាខណ្ឌដដែល) ។

ការផ្ញើដោយកូនបំណុលទី ៣ ក្នុងករណីដែលការរឹបអូសសិទ្ធិលើបំណុលដែលមានបំណងឱ្យសងជាប្រាក់ ត្រួតគ្នា (មាត្រា ៤១១ កថាខណ្ឌទី ២, ដែលហៅថា "ការផ្ញើដោយមានករណីយកិច្ច) :

តុលាការអនុវត្ត ( កថាខណ្ឌដដែល)

ការផ្ញើដោយកូនបំណុលទី ៣ ដែលបានទទួលការបង្គាប់ឱ្យសងប្រាក់តាមវិធីផ្ញើ ( មាត្រា ៤១១ កថាខណ្ឌទី ៣) តាមសាលក្រមដែលទទួលស្គាល់ការទាមទារក្នុងបណ្ដឹងទាមទារប្រមូលបំណុល ( មាត្រា ៤១២) :

សាលក្រមដែលទទួលស្គាល់ការទាមទារនៅក្នុងបណ្ដឹងទាមទារប្រមូលបំណុល មានខ្លឹមសារបង្គាប់ឱ្យកូនបំណុលទី ៣ ផ្ញើប្រាក់តាមបញ្ញត្តិនៃមាត្រា ៤១១ កថាខណ្ឌទី ២ ហេតុដូច្នេះ អាចបកស្រាយថា តុលាការដែលមានសមត្ថកិច្ចចំពោះការផ្ញើនេះ គឺតុលាការអនុវត្ត ដូចករណីដែលមានចែងក្នុងកថាខណ្ឌទី ២ នោះ ។

ការផ្ញើ ក្នុងករណីដែលតុលាការអនុវត្តបង្គាប់ឱ្យជនដែលមានករណីយកិច្ចបង់ថ្លៃឈ្នួល ផ្ញើប្រាក់ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដែលបានរឹបអូសនូវសិទ្ធិលើបំណុលចំពោះថ្លៃឈ្នួល ក្នុងនីតិវិធីនៃការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិលើប្រាតិភោគ ( មាត្រា ៥១៦ កថាខណ្ឌទី ២):

តុលាការអនុវត្ត ( កថាខណ្ឌដដែល) ។

ការផ្ញើដោយអាជ្ញាសាលា ក្នុងករណីដែលអាជ្ញាសាលាបានលក់ចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ( មាត្រា ៥២៤ កថាខណ្ឌទី ៧) :

សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ( កថាខណ្ឌដដែល) ។

ការផ្ញើដោយអាជ្ញាសាលា ក្នុងករណីដែលអាជ្ញាសាលាបានលក់ចលនវត្ថុដែលអាជ្ញាសាលាដកយកពីកូនបំណុលនៃការអនុវត្ត ហើយថែរក្សាគ្រប់គ្រង ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ ( មាត្រា ៥២៥ កថាខណ្ឌទី ៤, មាត្រា ៥២៤ កថាខណ្ឌទី ៧) :

សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ ( មាត្រា ៥២៥ កថាខណ្ឌទី ៤, មាត្រា ៥២៤ កថាខណ្ឌទី ៧) ។

ការផ្ញើប្រាក់ ឬ ឧបករណ៍អាចជួញដូរបាន សម្រាប់ការដាក់ប្រាតិភោគ ដោយអនុលោមតាមបញ្ញត្តិនៃគន្ថីទី ៧ ( ការចាត់ចែងរក្សាការពារ) ( មាត្រា ៥៣៦) :

តុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ ឬ តុលាការអនុវត្តការរក្សាការពារ ( មាត្រាដដែល) ។

ការផ្ញើប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន ( មាត្រា ៥៤៧ កថាខណ្ឌទី ១) :

តុលាការដែលបានចេញដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ឬ តុលាការអនុវត្តការរក្សាការពារ ( មាត្រាដដែល កថាខណ្ឌទី ២) ។

ការផ្ញើប្រាក់ដែលបានរឹបអូសជាបណ្ដោះអាសន្ន ដោយអាជ្ញាសាលា ( មាត្រា ៥៦៥ កថាខណ្ឌទី ១) :

តុលាការដែលអាជ្ញាសាលាស្ថិតនៅ ( កថាខណ្ឌដដែល) ។

ការផ្ញើថ្លៃលក់ចលនវត្ថុដែលបានរឹបអូសជាបណ្ដោះអាសន្ន ក្នុងករណីដែលមានការបារម្ភថា តម្លៃនៃចលនវត្ថុ

នោះនឹងធ្លាក់ចុះយ៉ាងខ្លាំង ឬ បើត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ ( មាត្រា ៥៦៥ កថាខណ្ឌទី ៣) :

តុលាការដែលអាជ្ញាសាលាស្ថិតនៅ ( កថាខណ្ឌដដែល) ។

ការផ្ញើដែលធ្វើដោយកូនបំណុលទី ៣ ក្នុងករណីអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ចំពោះសិទ្ធិលើបំណុលដែលមានបំណងឱ្យសងជាប្រាក់ ( មាត្រា ៥៦៦ កថាខណ្ឌទី ៥, មាត្រា ៤១១ កថាខណ្ឌទី ១) :

តុលាការអនុវត្តការរក្សាការពារ ( មាត្រា ៥២៥ កថាខណ្ឌទី ៤, មាត្រា ៥២៤ កថាខណ្ឌទី ៧) ។

ការផ្ញើដោយកូនបំណុលទី ៣ ក្នុងករណីការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន ត្រួតគ្នាជាមួយការរឹបអូសចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ( មាត្រា ៥៦៦ កថាខណ្ឌទី ៥, មាត្រា ៤១១ កថាខណ្ឌទី ២) :

តុលាការអនុវត្តការរក្សាការពារ ( មាត្រា ៥៦៦ កថាខណ្ឌទី ៥, មាត្រា ៤១១ កថាខណ្ឌទី ២) ។

## **ប្រការ ៥**.- ការប្រគល់នូវច្បាប់ដើមនៃឯកសារភ្ជាប់

១-ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងលិខិតពាក្យសុំ និង លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ អ្នកដាក់លិខិតនោះអាចទាមទារឱ្យប្រគល់ នៅពេលដាក់លិខិតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តចំពោះលិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិ ។

២-ដើម្បីទាមទារឱ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់លិខិតពាក្យសុំ ឬ លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវភ្ជាប់ជាមួយនឹងលិខិតនោះ នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះ គ្មានភាពខុសពីច្បាប់ដើម ។

៣-ក្នុងករណីដែលប្រគល់នូវច្បាប់ដើមនៃឯកសារភ្ជាប់ ក្រឡាបញ្ជីត្រូវឱ្យអ្នកទទួលការប្រគល់ សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវការណ៍ដែលខ្លួន បានទទួលការប្រគល់ឯកសារនោះ និង ចុះហត្ថលេខា ។

( កំណត់)

សូមមើលមាត្រា ៩-២ នៃបទប្បញ្ញត្តិស្តីពីការតម្កល់ នៃប្រទេសជប៉ុន ។

ប្រការនេះចែងអំពីការប្រគល់នូវច្បាប់ដើមនៃឯកសារដែលត្រូវបានភ្ជាប់ជាមួយនឹងលិខិតពាក្យសុំផ្ញើ ឬ លិខិត

ទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ។

ចំពោះលិខិតពាក្យសុំផ្ញើ ឬ លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ អ្នកដែលដាក់លិខិតនោះ ត្រូវភ្ជាប់នូវឯកសារមួយចំនួនជាកំណត់ (សូមមើលប្រការ ៦ និង ប្រការ ១៤ ជាអាទិ៍) ។ ឯកសារទាំងនេះ ត្រូវបានដាក់ដើម្បីឱ្យក្រឡាបញ្ជីយកមកធ្វើជាមូលដ្ឋានក្នុងការវិនិច្ឆ័យអំពីល័ក្ខខ័ណ្ឌនៃការផ្ញើ ឬ ការប្រគល់នូវវត្ថុផ្ញើ ហេតុដូច្នេះ អ្នកដែលដាក់លិខិតពាក្យសុំផ្ញើ ឬ លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវដាក់ច្បាប់ដើមនៃឯកសារទាំងនោះ ។ ប៉ុន្តែក្នុងករណីដែលអ្នកដែលដាក់លិខិតពាក្យសុំផ្ញើ ឬ លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ទាមទារឱ្យប្រគល់ច្បាប់ដើមនៃឯកសារនោះ ក្រឡាបញ្ជីអាចប្រគល់ឯកសារនោះបាន ក្រោយពេលធ្វើការវិនិច្ឆ័យអំពីល័ក្ខខ័ណ្ឌនៃការផ្ញើ ឬ ការប្រគល់នូវវត្ថុផ្ញើ ។

អាស្រ័យហេតុនេះ កថាខណ្ឌទី ១ កំណត់ថា ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងលិខិតពាក្យសុំ និង លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ អ្នកដាក់លិខិតនោះអាចទាមទារឱ្យប្រគល់ នៅពេលដាក់លិខិតនោះ ។ ប៉ុន្តែចំពោះលិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិវិញ ដោយសារលិខិតនោះត្រូវបានធ្វើឡើងដើម្បីដាក់ពាក្យសុំផ្ញើ ឬ ទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ គ្មានភាពចាំបាច់ក្នុងការប្រគល់លិខិតនេះ ហេតុដូច្នេះ លិខិតបញ្ជាក់នោះ មិនត្រូវបានបញ្ចូលនូវកម្មវត្ថុនៃការប្រគល់ ។

ឯកសារភ្ជាប់ គឺជាឯកសារចាំបាច់ដើម្បីឱ្យមានមូលដ្ឋាននៃភាពត្រឹមត្រូវក្នុងការវិនិច្ឆ័យអំពីពាក្យសុំផ្ញើ ឬ ការទាមទារឱ្យប្រគល់វត្ថុផ្ញើ ហេតុនេះបានជាកថាខណ្ឌទី ២ តម្រូវឱ្យអ្នកដាក់លិខិតពាក្យសុំ ឬ លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ភ្ជាប់ជាមួយនឹងលិខិតនោះ នូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះ គ្មានភាពខុសពីច្បាប់ដើម ក្នុងករណីដែលអ្នកនោះទាមទារឱ្យប្រគល់នូវច្បាប់ដើមនៃឯកសារនោះ ហើយក្រឡាបញ្ជីអាចរក្សាទុកនូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នោះ ជំនួសច្បាប់ដើម ។ កថាខណ្ឌទី ៣ ចែងថា នៅពេលក្រឡាបញ្ជីប្រគល់នូវច្បាប់ដើមនៃឯកសារភ្ជាប់ ក្រឡាបញ្ជីត្រូវសរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ នូវការណ៍ដែលប្រគល់នូវច្បាប់ដើម និង ចុះហត្ថលេខា ។

## ជំពូកទី ២
## នីតិវិធីធ្វើវត្ថុដែលជាកម្មវត្ថុនៃការធ្វើ

**ប្រការ ៦.-** ពាក្យសុំធ្វើ

១-អ្នកដាក់ពាក្យសុំធ្វើ ត្រូវដាក់ទៅក្រឡាបញ្ជី នូវលិខិតពាក្យសុំធ្វើមួយច្បាប់សម្រាប់អ្នកធ្វើ និង មួយច្បាប់សម្រាប់តុលាការ តាមទម្រង់ពីលេខ ១ ដល់លេខ ៦ នៃឧបសម្ព័ន្ធ ទៅតាមប្រភេទនៃការធ្វើ ដោយភ្ជាប់ជាមួយនឹងវត្ថុដែលជាកម្មវត្ថុនៃការធ្វើ ។

២-លិខិតពាក្យសុំធ្វើដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរចូលនូវចំណុចដូចខាងក្រោម ហើយត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកធ្វើ ឬ អ្នកតំណាងនីតិបុគ្គល (ក្នុងករណីដែលអ្នកធ្វើជានីតិបុគ្គល) ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិរបស់អ្នកធ្វើ :

ក-ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និង អាសយដ្ឋានរបស់អ្នកធ្វើ ។ ប្រសិនបើអ្នកធ្វើជានីតិបុគ្គល គឺ នាមករណ៍ ទីតាំងនៃទីស្នាក់ការជាចម្បង និង ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គលនោះ ។

ខ-ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ប្រសិនបើការធ្វើត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ។

គ-ចំនួនទឹកប្រាក់ធ្វើ ឬ ប្រសិនបើធ្វើឧបករណ៍អាចជួញដូរបាន គឺ ឈ្មោះនៃឧបករណ៍នោះ ចំនួនទឹកប្រាក់សរុប ចំនួនទឹកប្រាក់ក្នុងមួយសន្លឹក (ចំពោះឧបករណ៍អាចជួញដូរបានដែលគ្មានសរសេរចំនួនទឹកប្រាក់ទេ ត្រូវសរសេរការណ៍នោះ) លេខស៊េរី លេខរៀង ចំនួនសន្លឹក និង ចំណុចផ្សេងទៀតដែលសម្គាល់អត្តសញ្ញាណនៃឧបករណ៍នោះ ។

ឃ-អង្គហេតុដែលជាមូលហេតុនៃការធ្វើ ។

ង-បញ្ញត្តិច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងដែលតម្រូវ ឬ អនុញ្ញាតឱ្យធ្វើ ។

ច-ប្រសិនបើអាចកំណត់បញ្ជាក់អំពីអ្នកដែលអាចទាមទារឱ្យប្រគល់ឱ្យនូវប្រាក់ ឬ ឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើ (តទៅហៅថា "អ្នកមានសិទ្ធិទទួលពីការផ្ញើ") គឺ ឈ្មោះ និង អាសយដ្ឋានរបស់អ្នកមានសិទ្ធិទទួលពីការផ្ញើ ហើយប្រសិនបើជាអ្នកមានសិទ្ធិទទួលពីការផ្ញើជានីតិបុគ្គល គឺ នាមករណ៍ ទីតាំងនៃទីស្នាក់ការជាចម្បង និង ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គលនោះ ។

ឆ-ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្តីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ។

ជ-ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ ។

ឈ-ថ្ងៃ ខែ ឆ្នាំ ដាក់ពាក្យសុំផ្ញើ ។

(កំណត់)

១. ប្រការនេះ បញ្ញត្តអំពីនីតិវិធីនៃការដាក់ពាក្យសុំផ្ញើ ។ កថាខណ្ឌទី ១ ចែងថា ដើម្បីដាក់ពាក្យសុំផ្ញើ អ្នកដាក់ពាក្យសុំផ្ញើ ត្រូវដាក់ទៅក្រឡាបញ្ជី នូវលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ និង លិខិតពាក្យសុំផ្ញើសម្រាប់តុលាការ តាមទម្រង់ពីលេខ ១ ដល់លេខ ៦ ទៅតាមប្រភេទនៃការផ្ញើ ដោយដាក់ភ្ជាប់ជាមួយនូវវត្ថុដែលជាកម្មវត្ថុនៃការផ្ញើ ។ កថាខណ្ឌទី ២ ចង្អុលបង្ហាញនូវចំណុចដែលត្រូវសរសេរចូលទៅក្នុងលិខិតពាក្យសុំផ្ញើ ។

២. កថាខណ្ឌទី ១ ទាមទារឱ្យប្រើប្រាស់នូវទម្រង់ពីលេខ ១ ដល់លេខ ៦ អាស្រ័យទៅតាមប្រភេទនៃការផ្ញើ ពីព្រោះតែពាក្យសុំផ្ញើត្រូវបានធ្វើឡើងដោយមានលក្ខណៈជាទម្រង់កំណត់ ដោយផ្អែកទៅលើបញ្ញត្តិស្តីពីការផ្ញើ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ហើយក្រឡាបញ្ជីត្រូវចាត់ការកិច្ចការផ្ញើជាច្រើនដោយឆាប់រហ័សផងដែរ ។ ហេតុនេះហើយ ការសុំផ្ញើដោយមិនធ្វើជាលាយលក្ខណ៍អក្សរ (ដោយផ្ទាល់មាត់) ឬ ការដាក់ពាក្យសុំដោយមិនប្រើទម្រង់សមស្របពីលេខ ១ ដល់លេខ ៦ គឺខុសច្បាប់ ។

ខាងក្រោមនេះជាទម្រង់ដែលត្រូវប្រើទៅតាមប្រភេទនៃផ្ញើ :

ទម្រង់លេខ ១ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) ក្នុងករណីនៃការផ្ញើប្រាក់ដើម្បីជាប្រាតិភោគតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន ។

ទម្រង់លេខ ២ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) ក្នុងករណីនៃការផ្ញើប្រាក់ដើម្បីជាប្រាតិភោគតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន ។

ទម្រង់លេខ ៣ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) ក្នុងករណីនៃការផ្ញើឧបករណ៍អាចជួញដូរបានដើម្បី

ជាប្រាតិភោគតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន ។

ទម្រង់លេខ ៤ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) ក្នុងករណីនៃការផ្ញើឧបករណ៍អាចជួញដូរបាន ដើម្បីជាប្រាតិភោគតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន ។

ទម្រង់លេខ ៥ : លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) ក្នុងករណីនៃការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត ។

ទម្រង់លេខ ៦ : លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ) ក្នុងករណីនៃការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត ។

៣. តាមទស្សនៈ នីតិវិធីផ្ញើអាចបែងចែកជាពីរ គឺ នីតិវិធីវិនិច្ឆ័យថា ត្រូវទទួលការផ្ញើឬអត់ និង នីតិវិធីនៃសកម្មភាពជាក់ស្តែងនៃការដាក់ និង ទទួលវត្ថុដែលជាកម្មវត្ថុនៃការផ្ញើ ។ ក៏ប៉ុន្តែ ដើម្បីអនុវត្តនីតិវិធីផ្ញើឱ្យបានឆាប់រហ័ស និង យ៉ាងសាមញ្ញ ការណ៍ដែលទាមទារឱ្យអ្នកដាក់ពាក្យសុំផ្ញើ ដាក់វត្ថុដែលជាកម្មវត្ថុនៃការដាក់ផ្ញើព្រមជាមួយគ្នានឹងដាក់ពាក្យសុំផ្ញើ ហើយទទួលនូវវត្ថុនោះតែម្តងនៅពេលទទួលពាក្យសុំនោះ គឺសមរម្យហើយ ។ ដោយហេតុនេះហើយបានជាកថាខណ្ឌទី ១ នៃប្រការនេះចែងថា អ្នកសុំផ្ញើ ត្រូវដាក់លិខិតពាក្យសុំជាលាយល័ក្ខណ៍អក្សរទៅក្រឡាបញ្ជីដោយភ្ជាប់មកជាមួយនូវវត្ថុដែលជាកម្មវត្ថុនៃការផ្ញើផងដែរ ។ នៅពេលដែលក្រឡាបញ្ជីយល់ឃើញថា ត្រូវទទួលពាក្យសុំផ្ញើ វត្ថុផ្ញើក៏ត្រូវបានទទួលនៅពេលនោះតែម្តងដែរ ហើយទំនាក់ទំនងនៃការផ្ញើក៏ត្រូវបានបង្កើតឡើង ។

ចំពោះការទទួលវត្ថុផ្ញើ ក្នុងនីតិវិធីតម្កល់នៅប្រទេសជប៉ុន ការិយាល័យតម្កល់ខ្លះទទួលសាច់ប្រាក់ និងការិយាល័យតម្កល់ខ្លះមិនទទួលសាច់ប្រាក់ ហើយការិយាល័យតម្កល់ដែលមិនទទួលសាច់ប្រាក់ តម្រូវឱ្យអ្នកតម្កល់បង់ប្រាក់តម្កល់ទៅធនាគារជាតិជប៉ុន ឬ ទៅទីភ្នាក់ងារនៃធនាគារជាតិនោះ ដោយផ្ទាល់តែម្តង បន្ទាប់ពីមានការសម្រេចទទួលយកការតម្កល់ ។ ដោយឡែក ចំពោះឧបករណ៍អាចជួញដូរបានវិញ ដោយព្រោះពុំមានការិយាល័យតម្កល់ណាមួយទទួលឧបករណ៍អាចជួញដូរបានទេ នីតិវិធីទទួលការផ្ញើឧបករណ៍អាចជួញដូរបាននោះ គឺអនុវត្តដូចគ្នានឹងនីតិវិធីនៅការិយាល័យដែលមិនទទួលសាច់ប្រាក់នោះដែរ ។ ការអនុវត្តបែបនេះ គឺដោយសារតែនៅប្រទេសជប៉ុន តុលាការមិនថែរក្សាគ្រប់គ្រងនូវសាច់ប្រាក់ ឬ ឧបករណ៍អាចជួញដូរបានទេ ប៉ុន្តែ គឺធនាគារជាតិជប៉ុនទេដែលទទួលចាត់ចែងកិច្ចការទាំងនេះ ( ប្រាក់ដែលរដ្ឋរក្សាទុក គឺត្រូវឱ្យធនាគារជាតិជប៉ុន គ្រប់គ្រងតាមមធ្យោបាយឯកភាពមួយ ។ ប្រសិនបើប្រាក់ត្រូវបានតម្កល់នៅការិយាល័យតម្កល់ដែលអាចទទួលសាច់ប្រាក់ នៅទីបំផុតក៏ត្រូវផ្ទេរទៅធនាគារជាតិជប៉ុន ឬ ទៅទីភ្នាក់ងារធនាគារជាតិជប៉ុន តាមរយៈនីតិវិធីរបស់ការិយាល័យតម្កល់ ។ ការអនុវត្តបែបនេះ ប្រហែលជាអាចមានឱកាសដើម្បីធ្វើការពិចារណា ដោយអាស្រ័យទៅលើស្ថានភាពរបស់ប្រទេសកម្ពុជា ។ ប៉ុន្តែ នៅក្នុងសេចក្តីព្រាងប្រកាសនេះ ដើម្បីឱ្យមានភាពច្បាស់លាស់ និង ភាពងាយស្រួលនៃ

នីតិវិធី ប្រការនេះកំណត់ថា តុលាការត្រូវទទួលវត្ថុដែលជាកម្មវត្ថុនៃការផ្ញើដោយផ្ទាល់តែម្តង ។ ចំពោះចំណុចនេះ សូមឱ្យភាគីកម្ពុជាពិនិត្យមើលជាបន្តទៀតទៅ ។
៤. កថាខណ្ឌទី ២ នៃប្រការនេះ ចែងអំពីចំណុចដែលត្រូវសរសេរក្នុងលិខិតពាក្យសុំផ្ញើ ។ ទម្រង់នៃលិខិតពាក្យសុំពីលេខ ១ ដល់លេខ ៦ មានទុកកន្លែងទំនេរសម្រាប់សរសេរចំណុចទាំងនោះ ហើយពាក្យសុំនោះនឹងអាចបំពេញបានប្រសិនបើទម្រង់ពាក្យសុំត្រូវបានជ្រើសរើសត្រឹមត្រូវតាមប្រភេទនៃការដាក់ផ្ញើ ហើយកន្លែងទំនេរនោះនឹងត្រូវបំពេញចូល ។

## ប្រការ ៧.- ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំផ្ញើ

១-ប្រសិនបើនីតិបុគ្គលមានបំណងផ្ញើ នីតិបុគ្គលនោះត្រូវភ្ជាប់ជាមួយនឹងលិខិតពាក្យសុំផ្ញើ នូវលិខិតបញ្ជាក់លក្ខណសម្បត្តិរបស់អ្នកតំណាងនៃនីតិបុគ្គលនោះ ។

២-ប្រសិនបើការផ្ញើត្រូវបានធ្វើឡើងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ត្រូវភ្ជាប់ជាមួយនឹងលិខិតពាក្យសុំផ្ញើ នូវលិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងនោះ ។

(កំណត់)
១. មាត្រានេះចែងអំពីលិខិតដែលត្រូវដាក់ភ្ជាប់ជាមួយនឹងពាក្យសុំដាក់ផ្ញើ ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងនីតិវិធីផ្ញើ នូវសិទ្ធិរបស់អ្នកតំណាងនីតិបុគ្គល ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ដែលបានដាក់ពាក្យសុំផ្ញើ ពាក្យសុំផ្ញើត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់លក្ខណសម្បត្តិ របស់អ្នកតំណាងនីតិបុគ្គលនោះ (ក្នុងករណីដែលនីតិបុគ្គលមានបំណងផ្ញើ) ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ (ក្នុងករណីដែលអ្នកផ្ញើមានបំណងផ្ញើតាមរយៈអ្នកតំណាងនោះ) ។
២. ក្នុងករណីដែលនីតិបុគ្គលដាក់ពាក្យសុំផ្ញើ អ្នកតំណាងរបស់នីតិបុគ្គលនោះ នឹងធ្វើនីតិវិធីផ្ញើ ក្នុងនាមជានីតិបុគ្គលនោះ ។ ក្នុងករណីនេះ ដោយសារតែអ្នកតំណាងនោះត្រូវធ្វើការបញ្ជាក់ថា ខ្លួនមានសិទ្ធិតំណាងនីតិបុគ្គលពិតមែន កថាខណ្ឌទី ១ កំណត់ថា លិខិតបញ្ជាក់លក្ខណសម្បត្តិនៃអ្នកតំណាង ត្រូវតែភ្ជាប់មកជាមួយពាក្យសុំ ។
៣. ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ដាក់ពាក្យសុំផ្ញើ ចាំបាច់ត្រូវបញ្ជាក់ថា ខ្លួនមានសិទ្ធិអំណាចក្នុងការតំណាងម្ចាស់សិទ្ធិពិតមែន ។ ដោយហេតុនេះ បានជាកថាខណ្ឌទី ២ ចែងថា ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងនោះ ។ អ្នកតំណាងរួមបញ្ចូលមានអ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិ ។ ចំពោះអ្នកតំណាងដែលត្រូវបានជ្រើសតាំងដោយតុលាការ

ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសេចក្តីសម្រេចជ្រើសតាំងនោះ គឺជាឯកសារបញ្ជាក់សិទ្ធិតំណាង រីឯចំពោះអ្នកតំណាងដោយអាណត្តិ លិខិតប្រគល់សិទ្ធិ អាចត្រូវបានភ្ជាប់ជាលិខិតបញ្ជាក់សិទ្ធិ ។

ប្រសិនបើលិខិតបញ្ជាក់សិទ្ធិតំណាង ជាលិខិតប្រគល់សិទ្ធិដែលម្ចាស់សិទ្ធិបានរៀបចំ ក្នុងនាមជាបុគ្គលឯកជន នឹងមានបញ្ហាកើតឡើង ចំពោះចំណុចថា តើតុលាការអាចនឹងមើលដឹងថា លិខិតប្រគល់សិទ្ធិត្រូវបានធ្វើឡើងស្របជាមួយនឹងឆន្ទៈរបស់សាមីខ្លួនដែរឬយ៉ាងណា ។ នៅប្រទេសជប៉ុន ដើម្បីបញ្ជាក់អត្តសញ្ញាណសាមីខ្លួន មានរបបចុះបញ្ជីត្រាអនុសិដ្ឋ និង របបបញ្ជាក់ត្រាអនុសិដ្ឋ ហើយជាទូទៅ គេប្រើរបបទាំងនេះគ្រប់ៗគ្នា ។ ប្រសិនបើនៅកម្ពុជា មានរបបផ្សេងទៀតដែលអាចប្រើ ដើម្បីបញ្ជាក់ពីអត្តសញ្ញាណសាមីខ្លួនបាន របបនោះនឹងត្រូវយកមកប្រើ ។ ក្នុងករណីនេះ ដោយសារតែមើលទៅឃើញថា សមរម្យក្នុងការញ្ចូលចំណុចនេះនៅក្នុងបញ្ញត្តិច្បាប់ដូច្នេះសូមភាគីកម្ពុជាពិចារណា ហើយសម្រេចអំពីចំណុចនេះផង ។

## **ប្រការ ៨.-** ការផ្ញើឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះ

បុគ្គលដែលមានបំណងផ្ញើឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះ ត្រូវធ្វើបិដ្ឋិលេខន៍ (កាខ្នង) លើឧបករណ៍នោះ ឬ វិធានការផ្សេងទៀត ដើម្បីឱ្យអ្នកដែលទទួលការប្រគល់ឱ្យនូវឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះនោះ អាចធ្វើលទ្ធកម្មសិទ្ធិបានភ្លាមៗ ។

(កំណត់)

ចំពោះការផ្ញើឧបករណ៍អាចជួញដូរបាន ដែលមានកំណត់ឈ្មោះ ប្រសិនបើគ្មានបិដ្ឋិលេខន៍ (កាខ្នង) លើឧបករណ៍នោះ ឬ វិធានការផ្សេងទៀត ដើម្បីឱ្យអ្នកដែលទទួលការប្រគល់ឱ្យនូវឧបករណ៍អាចជួញដូរបានដែលមានកំណត់ឈ្មោះនោះ អ្នកដែលទទួលការប្រគល់ឱ្យនូវឧបករណ៍នោះ មិនអាចធ្វើលទ្ធកម្មសិទ្ធិបានភ្លាមៗទេ ហើយរបបនៃការផ្ញើនឹងបាត់បង់ប្រសិទ្ធភាព ។ ហេតុនេះហើយបានជា ប្រការនេះតម្រូវអ្នកផ្ញើចាត់នូវវិធានការដូចជាការធ្វើបិដ្ឋិលេខន៍ (កាខ្នង) នៅពេលដាក់ពាក្យសុំផ្ញើ ដើម្បីឱ្យបុគ្គលដែលទទួលការប្រគល់ឱ្យនូវឧបករណ៍នោះ អាចធ្វើលទ្ធកម្មសិទ្ធិភ្លាមៗបាន ។

## **ប្រការ ៩.-** ការផ្ញើដើម្បីការប្តូរប្រាតិភោគ

១-ការប្តូរវត្ថុផ្ញើដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី (រួមបញ្ចូលទាំង

ករណីដែលបញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមមាត្រា ៣៧៧ (ការដាក់ប្រាតិភោគ) កថាខណ្ឌទី ៤ នៃមាត្រា ៤៦១ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយដាក់ប្រាក់ធានា) និង មាត្រា ៥៣៦ (ការផ្តល់នូវប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី) ត្រូវអនុវត្តតាមវិធីដែលបុគ្គលដែលត្រូវផ្តល់ប្រាតិភោគ ធ្វើការផ្ញើជាថ្មី ដោយផ្អែកលើដីកាសម្រេចបង្គាប់ឱ្យប្តូរវត្ថុប្រាតិភោគរបស់តុលាការ ហើយក្រោយមក ទទួលការប្រគល់នូវវត្ថុដែលត្រូវបានផ្ញើពេលមុន ។

២-នៅពេលធ្វើការផ្ញើដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បុគ្គលដែលធ្វើការផ្ញើ ត្រូវបញ្ជាក់ថា គោលបំណងនៃការផ្ញើនេះគឺដើម្បីប្តូរប្រាតិភោគ ហើយត្រូវបញ្ជាក់អំពីខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យប្តូរប្រាតិភោគរបស់តុលាការ និង ចំណុចដែលអាចកំណត់នូវអត្តសញ្ញាណនៃវត្ថុដែលកំពុងត្រូវបានផ្ញើ ។

(កំណត់)

១. ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៧១ កថាខណ្ឌទី ២ មានចែងថា តុលាការអាចបង្គាប់ឱ្យប្តូរប្រាតិភោគ តាមពាក្យសុំរបស់អ្នកដែលបានដាក់ប្រាតិភោគនោះដោយដីកាសម្រេចបាន ។ ហើយបញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាតិភោគដែលត្រូវបានដាក់ដោយផ្អែកលើបញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) ដោយយោងតាមមាត្រា ៣៧៧ (ការដាក់ប្រាតិភោគ) និង ចំពោះប្រាក់ធានាដែលកូនបំណុលនៃការអនុវត្ត បានដាក់ដើម្បីដាក់ពាក្យសុំ ឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយយោងតាមកថាខណ្ឌទី ៤ នៃមាត្រា ៤៦១ (ការលុបចោលនីតិវិធីលក់ដោយបង្ខំ ដោយដាក់ប្រាក់ធានា) និង ចំពោះប្រាតិភោគដែលត្រូវបានដាក់ដោយផ្អែកលើបញ្ញត្តិនៃគន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) ដោយយោងតាមមាត្រា ៥៣៦ (ការផ្តល់នូវប្រាតិភោគ) ។ ការប្តូរប្រាតិភោគដោយផ្អែកលើបញ្ញត្តិខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេចស្តីពីការប្តូរប្រាតិភោគរបស់តុលាការ ប៉ុន្តែ ចំពោះវិធីប្តូរប្រាតិភោគ នៅមិនទាន់ច្បាស់លាស់ឡើយ ។ ហេតុនេះហើយបានជា ប្រការនេះបានចែងអំពីវិធីប្តូរប្រាតិភោគ ព្រមទាំងនីតិវិធីប្តូរ ដែលត្រូវបានធ្វើដោយផ្អែកលើដីកាសម្រេចឱ្យប្តូរប្រាតិភោគរបស់តុលាការ ដោយយោងតាមបញ្ញត្តិខាងលើនេះ ។ កថាខណ្ឌទី ១ ចែងថា ការប្តូរវត្ថុផ្ញើ ត្រូវធ្វើតាមវិធីដែលបុគ្គលដែលមានករណីយកិច្ចផ្តល់ប្រាតិភោគ ធ្វើការផ្ញើជាថ្មី ដោយផ្អែកលើដីកាសម្រេចឱ្យប្តូរប្រាតិភោគរបស់តុលាការ ហើយក្រោយមក ទទួលការប្រគល់នូវវត្ថុដែលត្រូវបានផ្ញើនាពេលមុន ។ កថាខណ្ឌទី ២ ចែងថា នៅពេលធ្វើការផ្ញើជាថ្មីដើម្បីប្តូរប្រាតិភោគ បុគ្គលដែលធ្វើការផ្ញើនោះ ត្រូវបញ្ជាក់ថា គោលបំណងនៃការផ្ញើនេះ គឺដើម្បីប្តូរប្រាតិភោគ

ហើយត្រូវបញ្ជាក់អំពីខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យប្តូរប្រាតិភោគរបស់តុលាការ ព្រមទាំងចំណុចដែលអាចកំណត់នូវអត្តសញ្ញាណនៃវត្ថុដែលកំពុងត្រូវបានផ្ញើ ។

២. ការប្តូរប្រាតិភោគ សំដៅទៅលើការណ៍ដែលបុគ្គលដែលបានផ្តល់ប្រាតិភោគ ប្តូរប្រាតិភោគដែលត្រូវបានដាក់ពីមុន ទៅប្រាតិភោគមួយថ្មីទៀត ដោយផ្អែកលើដីកាសម្រេចបង្គាប់ឱ្យប្តូរប្រាតិភោគរបស់តុលាការ ។ ការប្តូរប្រាតិភោគគឺជានីតិវិធីមួយដើម្បីប្តូរពីប្រាក់ដែលជាកម្មវត្ថុនៃការផ្ញើ ទៅជាឧបករណ៍អាចជួញដូរបាន ឬ ប្តូរពីឧបករណ៍អាចជួញដូរបាន ទៅជាឧបករណ៍អាចជួញដូរបានផ្សេងទៀត ឬ ជាប្រាក់ ។ ការប្តូរប្រាតិភោគនេះត្រូវបានធ្វើឡើង ក្នុងករណីដែលពេលកំណត់នៃការបង្វិលវិញនូវឧបករណ៍អាចជួញដូរបានដែលកំពុងត្រូវបានផ្ញើបានមកដល់ ហើយចាំបាច់ត្រូវទទួលការបង្វិលវិញនោះ ឬ ករណីដែលអ្នកផ្ញើត្រូវការប្រើប្រាស់ប្រាក់ដែលខ្លួនបានផ្ញើ ហើយមានបំណងជំនួសប្រាក់នោះដោយឧបករណ៍អាចជួញដូរបានដែលខ្លួនមានវិញ ជាដើម ។ តាមច្បាប់ស្តីពីការតម្កល់របស់ប្រទេសជប៉ុន ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃតម្កល់ ជាឧបករណ៍អាចជួញដូរបាន នៅពេលដែលមានការទាមទារពីអ្នកមានសិទ្ធិទទួលឧបករណ៍អាចជួញដូរបាននោះ ការិយាល័យតម្កល់អាចទទួលនូវប្រាក់ដែលមកពីការបង្វិល (ប្រាក់លោះ) ការប្រាក់ ឬ ប្រាក់ចំណែក និង ធ្វើការថែរក្សាប្រាក់នោះជំនួសវត្ថុតម្កល់ ឬ ជាវត្ថុចំណុះ (ដែលគេហៅថា ការតម្កល់ជំនួស) ។ ថ្វីបើរបបបែបនេះបម្រើឱ្យផលប្រយោជន៍របស់អ្នកផ្ញើ (អ្នកតម្កល់) ក៏ប៉ុន្តែរបបនេះធ្វើឱ្យនីតិវិធីស្តីពីការផ្ញើស្មុគស្មាញណាស់ ហើយថែមទាំងបណ្តាលឱ្យមានបន្ទុកដ៏ធ្ងន់ដល់ក្រឡាបញ្ជីដែលចាត់ចែងកិច្ចការផ្ញើនេះទៀតផង ។ លើសពីនេះ ក្នុងករណីដែលបានបង្វិលវិញនូវឧបករណ៍អាចជួញដូរបាននេះ គេអាចទទួលលទ្ធផលប្រហាក់ប្រហែលគ្នាដែរ តាមរយៈនីតិវិធីប្តូរប្រាតិភោគ ដោយហេតុនេះហើយបានជាប្រកាសនេះមិនជ្រើសរើសវិធីនោះទេ ។ សូមភាគីកម្ពុជាពិនិត្យមើលទៅថា តើចាំបាច់មានរបបដូចនេះដែរឬយ៉ាងណា ។

នីតិវិធីប្តូរប្រាតិភោគ ត្រូវធ្វើឡើងតាមវិធីដែលអ្នកផ្ញើ ធ្វើការផ្ញើជាថ្មី ដោយផ្អែកលើដីកាសម្រេចឱ្យប្តូរប្រាតិភោគរបស់តុលាការ យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃប្រការនេះ ហើយទទួលការប្រគល់វិញនូវវត្ថុដែលត្រូវបានផ្ញើនាពេលមុន។ ដើម្បីធ្វើនីតិវិធីប្តូរប្រាតិភោគ ចាំបាច់ត្រូវមានដីកាសម្រេចឱ្យប្តូរប្រាតិភោគរបស់តុលាការ ហេតុដូច្នេះ អ្នកផ្ញើពុំអាចធ្វើនីតិវិធីប្តូរវត្ថុផ្ញើដោយពុំមានដីកាសម្រេចឱ្យប្តូរប្រាតិភោគរបស់តុលាការបានឡើយ ។ បើទោះជាមានការផ្ញើពីរ សម្រាប់គោលបំណងនៃប្រាតិភោគតែមួយ ក្នុងពេលតែមួយជាបណ្តោះអាសន្នក៏ដោយ ក៏វាជាស្ថានភាពដែលមិនអាចចៀសរួចបានដែរ ដោយហេតុថា តាមសភាពជាក់ស្តែង គេមិនអាចប្តូរវត្ថុដែលជាកម្មវត្ថុនៃការផ្ញើក្នុងពេលតែមួយបានទេ ។

ដើម្បីឱ្យអាចដឹងច្បាស់លាស់អំពីទំនាក់ទំនងរវាងការផ្ញើចាស់ និង ការផ្ញើថ្មី នីតិវិធីនៃការផ្ញើថ្មីតម្រូវឱ្យបញ្ជាក់ច្បាស់លាស់នូវចំណុចដែលមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ ហើយក្រៅពីនេះ ត្រូវអនុវត្តដូចគ្នានឹងនីតិវិធី

នៃការផ្ញើធម្មតាដែរ ។

តាមនីតិវិធីប្តូរប្រាតិភោគ ក្រោយពេលធ្វើការផ្ញើថ្មី អ្នកផ្ញើនោះត្រូវធ្វើនីតិវិធីនៃការប្រគល់វិញនូវវត្ថុដែលបានផ្ញើពីមុន ។ ចំពោះនីតិវិធីនៃការប្រគល់វិញនូវវត្ថុដែលបានផ្ញើពីមុននេះ គឺដូចគ្នានឹងនីតិវិធីទាមទារឱ្យប្រគល់វិញធម្មតាដែរ ។ម្យ៉ាងទៀត មូលហេតុនៃការទាមទារឱ្យប្រគល់វិញ គឺ "ការរលត់នៃមូលហេតុនៃការផ្ញើ" ។

៣. ការផ្ញើថ្មីដើម្បីប្តូរប្រាតិភោគ ត្រូវបានធ្វើឡើង ដោយនឹងមានការទាមទារឱ្យប្រគល់វិញនូវវត្ថុដែលបានផ្ញើពីមុន នៅពេលក្រោយការផ្ញើថ្មីនោះ ដូច្នេះហើយ ដើម្បីឱ្យនីតិវិធីប្រគល់វិញនូវវត្ថុដែលបានផ្ញើ អាចធ្វើទៅបានដោយរលូន ចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់លាស់នូវវត្ថុដែលបានផ្ញើពីមុន ហើយបញ្ជាក់ឱ្យច្បាស់លាស់ផងដែរថា ការផ្ញើថ្មីនេះមិនមែនជាការផ្ញើធម្មតាទេ គឺជាការផ្ញើដើម្បីប្តូរប្រាតិភោគ ។ ហេតុនេះហើយ កថាខណ្ឌទី ២ នៃប្រការនេះមានចែងថា នៅពេលធ្វើការផ្ញើថ្មីដើម្បីប្តូរប្រាតិភោគ អ្នកផ្ញើចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ថា ការផ្ញើនេះគឺដើម្បីប្តូរប្រាតិភោគ ហើយត្រូវបញ្ជាក់អំពីខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យប្តូរប្រាតិភោគរបស់តុលាការ ព្រមទាំងចំណុចដែលអាចកំណត់នូវវត្ថុដែលកំពុងត្រូវបានផ្ញើ ។

## **ប្រការ ១០**.- នីតិវិធីទទួលពាក្យសុំផ្ញើ

ប្រសិនបើយល់ឃើញថា ត្រូវទទួលពាក្យសុំផ្ញើ ក្រឡាបញ្ជីត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ នូវការណ៍ដែលទទួលពាក្យសុំផ្ញើ ការណ៍ដែលទទួលវត្ថុផ្ញើ និង លេខផ្ញើ រួចចុះហត្ថលេខា ហើយត្រូវប្រគល់លិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើនោះទៅឱ្យអ្នកផ្ញើ ។

(កំណត់)

អ្នកដែលមានបំណងផ្ញើនៅតុលាការ ត្រូវដាក់ពាក្យសុំផ្ញើទៅក្រឡាបញ្ជីដែលជាស្ថាប័នទទួលបន្ទុកកិច្ចការផ្ញើដោយផ្អែកលើបញ្ញត្តិដែលជាមូលដ្ឋាននៃការផ្ញើ ។ នៅពេលទទួលពាក្យសុំហើយ ក្រឡាបញ្ជីត្រូវវិនិច្ឆ័យថា តើត្រូវទទួលពាក្យសុំនេះ ឬ ត្រូវលើកចោល ។ ប្រការនេះមានចែងថា ក្រឡាបញ្ជីត្រូវធ្វើការចាត់ចែងទទួលពាក្យសុំផ្ញើ ប្រសិនបើក្រឡាបញ្ជីនោះយល់ឃើញថា ពាក្យសុំនោះបានបំពេញល័ក្ខខ័ណ្ឌផ្ញើគ្រប់គ្រាន់ ហើយអាចទទួលបាន ។ ប្រការនេះចែងផងដែរថា ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវចុះនូវការណ៍ដែលទទួលពាក្យសុំផ្ញើ ការណ៍ដែលទទួលវត្ថុផ្ញើ ចុះលេខផ្ញើ និង ចុះហត្ថលេខា នៅក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ ហើយត្រូវប្រគល់លិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើនោះ ទៅឱ្យអ្នកផ្ញើ ។ តាមការប្រគល់លិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើនោះ ការជូនដំណឹងអំពីការចាត់ចែងទទួលពាក្យសុំផ្ញើ ហើយអានុភាពនៃការចាត់ចែងទទួលពាក្យសុំផ្ញើនេះ នឹងកើតឡើង ។ ការចុះលេខផ្ញើ

គឺដើម្បី កំណត់អត្តសញ្ញាណការផ្ញើ ហើយនៅពេលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ជាដើម ចាំបាច់សរសេរនូវលេខផ្ញើ នោះ នៅក្នុងពាក្យសុំ ។

**ប្រការ ១១**.- បញ្ញត្តិពិសេសអំពីការទទួលប្រាក់ផ្ញើ

១-ចំពោះការផ្ញើប្រាក់ ប្រសិនបើមានការស្នើសុំរបស់បុគ្គលដែលមានបំណងផ្ញើ ក្រឡាបញ្ជីអាចទទួលការផ្ទេរប្រាក់ផ្ញើនៅក្នុងគណនីរបស់ក្រឡាបញ្ជី (តុលាការ) បាន ជំនួសការដាក់ប្រាក់ ដោយយោងតាមបញ្ញត្តិនៃប្រការ ៦ (ពាក្យសុំផ្ញើ) ។ ក្នុងករណីនេះ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៦ នោះក៏ដោយ ក៏បុគ្គលដែលមានបំណងផ្ញើប្រាក់ ត្រូវដាក់ទៅក្រឡាបញ្ជីនូវលិខិតពាក្យសុំផ្ញើមួយច្បាប់សម្រាប់អ្នកផ្ញើ និង មួយច្បាប់សម្រាប់តុលាការ តាមទម្រង់ពីលេខ ៧ ដល់លេខ ១០ នៃឧបសម្ព័ន្ធ ទៅតាមប្រភេទនៃការផ្ញើដែរ ។

២-ក្នុងករណីដែលមានការស្នើសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថា ត្រូវទទួលការផ្ញើដែលបានកំណត់នៅក្នុងកថាខណ្ឌដដែលនេះ ក្រឡាបញ្ជីត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ នូវការណ៍ដែលទទួលពាក្យសុំផ្ញើ លេខផ្ញើ និង កាលបរិច្ឆេទនៃការទទួលផ្ញើ រួចចុះហត្ថលេខា ហើយត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់តុលាការ នូវកាលបរិច្ឆេទនៃការទទួលផ្ញើ និង ចុះហត្ថលេខា ហើយត្រូវសរសេរនូវកាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ។ ក្រឡាបញ្ជីត្រូវរក្សាទុកនូវលិខិតពាក្យសុំផ្ញើទាំងពីរនោះ ។

៣-នៅពេលដែលក្រឡាបញ្ជីទទួលការផ្ញើ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ក្រឡាបញ្ជីត្រូវជូនដំណឹងទៅអ្នកផ្ញើអំពីការណ៍ដែលត្រូវផ្ទេរប្រាក់ផ្ញើមកគណនី រហូតដល់កាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ និង ការណ៍ដែលការសម្រេចទទួលការផ្ញើ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលបានកំណត់នោះ ដោយប្រគល់លិខិតជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ តាមទម្រង់លេខ ១១ ហើយត្រូវចុះ នៅក្នុងលិខិតស្នើសុំផ្ទេរប្រាក់ តាមទម្រង់លេខ ១២ នូវនាមករណ៍នៃស្ថាប័នហិរញ្ញវត្ថុ នៅចំណុច “ស្ថាប័នហិរញ្ញវត្ថុ”

លេខគណនី និង ឈ្មោះរបស់ម្ចាស់គណនី នៅចំណុច “អ្នកទទួលការផ្ទេរប្រាក់” និង ចំនួនទឹកប្រាក់ផ្ញើ នៅចំណុច “ចំនួនទឹកប្រាក់” រួចត្រូវប្រគល់ លិខិតស្នើសុំផ្ទេរប្រាក់ នោះ ទៅឱ្យអ្នកផ្ញើ ។

៤-កាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ត្រូវកំណត់ជាថ្ងៃដែលមានអំឡុងពេលមិនតិចជាង ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃទទួលការផ្ញើ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ត្រូវបានកំណត់នៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ សេចក្តីសម្រេចដែលបង្គាប់ឱ្យផ្ញើ ។

៥-ប្រសិនបើអ្នកផ្ញើមិនផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ការសម្រេចទទួលការផ្ញើត្រូវបាត់បង់អានុភាព ។

៦-ប្រសិនបើអ្នកផ្ញើផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក្រឡាបញ្ជីត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើនូវការណ៍ដែលទទួលប្រាក់ផ្ញើ រួចចុះហត្ថលេខា ហើយប្រគល់លិខិតពាក្យសុំសម្រាប់អ្នកផ្ញើនោះទៅឱ្យអ្នកផ្ញើ ។

(កំណត់)

១. ប្រការនេះ គឺជាបទប្បញ្ញត្តិពិសេស ដែលអនុញ្ញាតឱ្យទទួលការផ្ញើប្រាក់ តាមការផ្ទេរប្រាក់ផ្ញើនៅក្នុងគណនីរបស់ក្រឡាបញ្ជី (តុលាការ) ជំនួសការដាក់ប្រាក់ដោយយោងតាមបញ្ញត្តិនៃប្រការ ៦ ។

២. ប្រការ ៦ តម្រូវឱ្យអ្នកផ្ញើដាក់នូវលិខិតពាក្យសុំផ្ញើ ទៅក្រឡាបញ្ជី ដោយភ្ជាប់ជាមួយនឹងវត្ថុដែលជាកម្មវត្ថុនៃការផ្ញើ នៅពេលដាក់ពាក្យសុំផ្ញើ ហេតុដូច្នេះ ក្នុងករណីដែលផ្ញើប្រាក់ អ្នកផ្ញើត្រូវដាក់លិខិតពាក្យសុំផ្ញើ ដោយភ្ជាប់ជាមួយ ប្រាក់ដែលមានចំនួនស្មើនឹងចំនួនប្រាក់ត្រូវផ្ញើ ។ ប៉ុន្តែ ក្នុងករណីដូចជាករណីដែលប្រាក់ផ្ញើមានចំនួនច្រើនជាដើម អាចមានបញ្ហាអសន្តិសុខដល់អ្នកផ្ញើ ឬ អាចមានភាពងាយស្រួលសម្រាប់អ្នកផ្ញើ ក្នុងការផ្ទេរប្រាក់ផ្ញើក្នុងគណនី ជាងការដាក់សាច់ប្រាក់ផ្ទាល់ ។

ហេតុដូច្នេះ វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃប្រការនេះ ចែងថា ចំពោះការផ្ញើប្រាក់ ប្រសិនបើមានការស្នើសុំពីបុគ្គលដែលមានបំណងផ្ញើ ក្រឡាបញ្ជីអាចទទួលការផ្ទេរប្រាក់ផ្ញើនៅក្នុងគណនីរបស់ក្រឡាបញ្ជី (តុលាការ) បានជំនួសការដាក់ប្រាក់ ដោយយោងតាមបញ្ញត្តិនៃប្រការ ៦ ។ ក្នុងករណីនេះ អ្នកផ្ញើមិនចាំបាច់យកប្រាក់មកតុលាការ

ឡើយ ។

៣. ក្នុងករណីដែលដាក់ប្រាក់ជាមួយគ្នានឹងការដាក់ពាក្យសុំផ្ញើ ការសម្រេចទទួលការផ្ញើ និង ការទទួលវត្ថុផ្ញើ ត្រូវបានធ្វើឡើងព្រមជាមួយគ្នា ។ ហេតុដូច្នេះ ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ត្រូវទទួលការផ្ញើ ក្រឡាបញ្ជីនោះ អាចចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ នូវការណ៍ដែលទទួលពាក្យសុំផ្ញើ ការណ៍ដែលទទួលវត្ថុផ្ញើ និង លេខផ្ញើ រួចចុះហត្ថលេខា ហើយអាចប្រគល់លិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើនោះ ទៅឱ្យអ្នកផ្ញើ នៅពេលនោះបាន (សូមមើល ប្រការ ១០) ។ ប៉ុន្តែ ក្នុងករណីដែលធ្វើការផ្ញើតាមវិធីផ្ទេរប្រាក់ ការសម្រេចអំពីការទទួល ឬ មិនទទួលការផ្ញើ និង ការទទួលប្រាក់ផ្ញើ ត្រូវបានធ្វើឡើងនៅពេលផ្សេងគ្នា ។ ដោយសារមូលហេតុនេះ ក្រឡាបញ្ជីមិនអាចធ្វើការចាត់ចែង ដូចករណីខាងលើបានឡើយ ។ ហេតុដូច្នេះ បញ្ញត្តិពិសេសនៃប្រការ ១០ ត្រូវបានរៀបចំនៅកថាខណ្ឌទី ២ នៃ ប្រការនេះ ដោយចែងថា ការសម្រេចទទួលការផ្ញើ ត្រូវធ្វើឡើង ដោយយកការបង់ប្រាក់តាមការផ្ទេរប្រាក់មកធ្វើ ជាល័ក្ខខ័ណ្ឌ ។

៤. ដោយសារមូលហេតុខាងលើនេះ ខ្លឹមសារដែលត្រូវសរសេរនៅក្នុងលិខិតពាក្យសុំផ្ញើ ក៏មានចំណុចខុសពីលិខិត ពាក្យសុំធម្មតា ។ ហេតុដូច្នេះ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ទាមទារឱ្យអ្នកផ្ញើដាក់លិខិតពាក្យសុំដែលមាន ទម្រង់ផ្សេងពីលិខិតពាក្យសុំដែលត្រូវប្រើប្រាស់ក្នុងករណីដែលដាក់ពាក្យសុំ និង ប្រាក់ផ្ញើ ព្រមជាមួយគ្នា ។

៥. កថាខណ្ឌទី ៣ ដល់ កថាខណ្ឌទី ៦ កំណត់អំពីនីតិវិធីលំអិតនៃការផ្ញើតាមវិធីផ្ទេរប្រាក់ទៅគណនី ។

នីតិវិធីនៃការផ្ញើតាមវិធីផ្ទេរប្រាក់ មានដូចខាងក្រោម :

(១) បុគ្គលដែលមានបំណងផ្ញើប្រាក់ ត្រូវដាក់ទៅក្រឡាបញ្ជីនូវលិខិតពាក្យសុំផ្ញើមួយច្បាប់សម្រាប់អ្នកផ្ញើ និង មួយច្បាប់សម្រាប់តុលាការ តាមទម្រង់ពីលេខ ៧ ដល់លេខ ១០ នៃឧបសម្ព័ន្ធ ទៅតាមប្រភេទ នៃការផ្ញើដែរ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។

(២) ក្នុងករណីដែលមានការស្នើសុំខាងលើនេះ ប្រសិនបើយល់ឃើញថា ត្រូវទទួលការផ្ញើនោះ ក្រឡាបញ្ជី ត្រូវចុះក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ នូវការណ៍ដែលទទួលពាក្យសុំផ្ញើ លេខផ្ញើ និង កាលបរិច្ឆេទនៃ ការទទួលផ្ញើ រួចចុះហត្ថលេខា ហើយត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់តុលាការ នូវកាលបរិច្ឆេទនៃការ ទទួលផ្ញើ និង ចុះហត្ថលេខា ហើយត្រូវសរសេរនូវកាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ។ ក្រឡាបញ្ជី ត្រូវរក្សាទុកនូវលិខិតពាក្យសុំផ្ញើទាំងពីរនោះ ។

(៣) នៅពេលដែលក្រឡាបញ្ជីទទួលការផ្ញើ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃប្រការនេះ ក្រឡាបញ្ជី ត្រូវជូនដំណឹងទៅអ្នកផ្ញើអំពីការណ៍ដែលត្រូវផ្ទេរប្រាក់ផ្ញើមកគណនី រហូតដល់កាលបរិច្ឆេទកំណត់សម្រាប់ការ ផ្ទេរប្រាក់ និង ការណ៍ដែលការសម្រេចទទួលការផ្ញើ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទដែលបានកំណត់នោះ ដោយប្រគល់លិខិតជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ តាមទម្រង់

លេខ ១១ ហើយត្រូវចុះ នៅក្នុងលិខិតស្នើសុំផ្ទេរប្រាក់ តាមទម្រង់លេខ ១២ នូវនាមករណ៍នៃស្ថាប័នហិរញ្ញវត្ថុ នៅចំណុច "ស្ថាប័នហិរញ្ញវត្ថុ" លេខគណនី និង ឈ្មោះរបស់ម្ចាស់គណនី នៅចំណុច "អ្នកទទួលការផ្ទេរប្រាក់" និង ចំនួនទឹកប្រាក់ផ្ញើ នៅចំណុច "ចំនួនទឹកប្រាក់" រួចត្រូវប្រគល់លិខិតស្នើសុំផ្ទេរប្រាក់នោះ ទៅឱ្យអ្នកផ្ញើ ។

ការប្រគល់លិខិតតាមទម្រង់លេខ ១១ គឺជាការជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ ។

(៤) កាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ត្រូវកំណត់ជាថ្ងៃដែលមានអំឡុងពេលមិនតិចជាង ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃទទួលការផ្ញើ ។ ប៉ុន្តែ ក្នុងករណីដែលកាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ ត្រូវបានកំណត់នៅក្នុង (ច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ) សេចក្តីសម្រេចដែលបង្គាប់ឱ្យផ្ញើ នោះត្រូវធ្វើទៅតាម (បញ្ញត្តិ ឬ) សេចក្តីសម្រេចនោះ ។

មូលហេតុដែលកំណត់អំឡុងពេល ១ សប្តាហ៍នេះ គឺ ដោយសារនីតិវិធីនៃការផ្ទេរប្រាក់ តម្រូវឱ្យមានពេលវេលាមួយចំនួន ហើយអាចមានករណីដែលមានថ្ងៃសម្រាកក្នុងអំឡុងពេលនោះ ។ អំឡុងពេលនេះអាចសម្រួលទៅតាមស្ថានភាពនៃប្រទេសកម្ពុជា ហេតុដូច្នេះ សូមគិតពិចារណា ។ ប៉ុន្តែ មានករណីខ្លះដែលអំឡុងពេលសម្រាប់ការដាក់ប្រាតិភោគ ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់តុលាការ ដូចជាប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ និង ប្រាតិភោគសម្រាប់ការចាត់ចែងរក្សាការពារ ជាអាទិ៍ ។ ក្នុងករណីនេះ កាលបរិច្ឆេទកំណត់សម្រាប់ការផ្ទេរប្រាក់ គួរតែកំណត់ឱ្យមានអំឡុងពេលដូចបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ លុះត្រាតែអាចដឹងអំពីអំឡុងពេលនេះ ។

(៥) ប្រសិនបើអ្នកផ្ញើមិនផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលក្រឡាបញ្ជីបានកំណត់ ការសម្រេចទទួលការផ្ញើត្រូវបាត់បង់អានុភាព ដោយស្វ័យប្រវត្តិ ។ ក្រឡាបញ្ជី មិនចាំបាច់ធ្វើការចាត់ចែងដូចជាការសម្រេចលុបចោលការសម្រេចទទួលការផ្ញើឡើយ ។ នេះគឺដោយសារការសម្រេចទទួលការផ្ញើ តាមវិធីផ្ទេរប្រាក់ត្រូវបានធ្វើឡើង ដោយយកការផ្ទេរប្រាក់តាមកាលបរិច្ឆេទជាកំណត់មកធ្វើជាល័ក្ខខ័ណ្ឌ ។

(៦) ប្រសិនបើអ្នកផ្ញើផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទដែលក្រឡាបញ្ជីបានកំណត់ ក្រឡាបញ្ជីត្រូវចុះ ក្នុងលិខិតពាក្យសុំផ្ញើសម្រាប់អ្នកផ្ញើ នូវការណ៍ដែលទទួលប្រាក់ផ្ញើ រួចចុះហត្ថលេខា ហើយប្រគល់ (ឬ ផ្ញើ) លិខិតពាក្យសុំសម្រាប់អ្នកផ្ញើនោះទៅឱ្យអ្នកផ្ញើ ។

## **ប្រការ ១២.**- ការលើកចោលនូវពាក្យសុំផ្ញើ

ប្រសិនបើយល់ឃើញថា មិនត្រូវទទួលពាក្យសុំផ្ញើទេ ក្រឡាបញ្ជីត្រូវធ្វើលិខិតលើកចោលពាក្យសុំ ហើយប្រគល់លិខិតនោះឱ្យអ្នកផ្ញើ ។

（កំណត់）

ដូចដែលមានសរសេរក្នុងកំណត់នៃប្រការ ១០ ក្រឡាបញ្ជីត្រូវធ្វើការវិនិច្ឆ័យថា តើត្រូវទទួល ឬ លើកចោលពាក្យសុំផ្ញើ ។ ប្រការនេះមានចែងថា ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ពាក្យសុំផ្ញើមិនបំពេញលក្ខខ័ណ្ឌ ហើយមិនត្រូវទទួលទេនោះ ក្រឡាបញ្ជីត្រូវធ្វើការចាត់ចែងលើកចោលពាក្យសុំនោះ ។ ប្រការនេះក៏បានចែងផងដែរថា ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើលិខិតលើកចោលពាក្យសុំដែលសរសេរអំពីខ្លឹមសារនៃការចាត់ចែងលើកចោលនោះ និង ប្រគល់លិខិតនោះទៅអ្នកដាក់ពាក្យសុំ ។ ដោយការប្រគល់លិខិតលើកចោល ការជូនដំណឹងអំពីការចាត់ចែងលើកចោល ត្រូវបានធ្វើឡើង ហើយអានុភាពនៃការចាត់ចែងលើកចោល នឹងកើតឡើង ។

# ជំពូកទី ៣
# នីតិវិធីប្រគល់នូវវត្ថុផ្ញើ

**ប្រការ ១៣.**- ការប្រគល់ឱ្យនូវវត្ថុផ្ញើ

ជនដែលទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ ត្រូវបញ្ជាក់ពីសិទ្ធិទាមទារឱ្យប្រគល់ឱ្យរបស់ខ្លួននោះ ដោយអនុលោមតាមបញ្ញត្តិនៃប្រកាសនេះ ។

(កំណត់)

១. នៅពេលដែលពាក្យសុំផ្ញើត្រូវបានទទួល ហើយទំនាក់ទំនងគតិយុត្តនៃការផ្ញើត្រូវបានបង្កើតឡើង នោះស្ថានភាពដែលតុលាការដែលទទួលការផ្ញើថែរក្សាគ្រប់គ្រងនូវវត្ថុផ្ញើ ត្រូវកើតឡើង ។ នីតិវិធីបញ្ចប់ទំនាក់ទំនងនៃការផ្ញើនេះ គឺជានីតិវិធីប្រគល់នូវវត្ថុផ្ញើ។

ការប្រគល់នូវវត្ថុផ្ញើមានពីរប្រភេទ គឺ "ការប្រគល់ឱ្យ" និង "ការប្រគល់វិញ" ។ ជាធម្មតា នៅពេលដែលទំនាក់ទំនងគតិយុត្តនៃការផ្ញើត្រូវបានបង្កើតឡើង អ្នកផ្ញើ និង អ្នកមានសិទ្ធិទទួលពីការផ្ញើដែលជាភាគីម្ខាងទៀតនៃអ្នកផ្ញើ ធ្វើលទ្ធកម្មនូវសិទ្ធិទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ (សិទ្ធិទាមទារឱ្យប្រគល់) ក្រោមល័ក្ខខ័ណ្ឌមួយចំនួន ។ ក្នុងចំណោមសិទ្ធិទាមទារឱ្យប្រគល់ សិទ្ធិទាមទារឱ្យប្រគល់របស់អ្នកមានសិទ្ធិទទួលពីការផ្ញើដែលជាម្ចាស់សិទ្ធិនៅក្នុងទំនាក់ទំនងនៃការផ្ញើ គឺជា "សិទ្ធិទាមទារឱ្យប្រគល់ឱ្យ" ហើយការប្រគល់វត្ថុផ្ញើទៅឱ្យអ្នកមានសិទ្ធិទទួលពីការផ្ញើ ឬ ប្រតិសិទ្ធិរបស់អ្នកនោះ ជាដើម ហៅថា "ការប្រគល់ឱ្យ" ។ តាមការប្រគល់ឱ្យនោះ ទំនាក់ទំនងគតិយុត្តនៃការផ្ញើនោះ បានសម្រេចគោលដៅ ហើយបានបញ្ចប់ ។

ផ្ទុយទៅវិញ សិទ្ធិទាមទារឱ្យប្រគល់ដែលអ្នកផ្ញើមាន ហៅថា "សិទ្ធិទាមទារឱ្យប្រគលវិញ" ហើយការប្រគល់វត្ថុផ្ញើទៅឱ្យអ្នកផ្ញើ ឬ ប្រតិសិទ្ធិរបស់អ្នកនោះ ហៅថា "ការប្រគល់វិញ" ។ "ការប្រគល់វិញ" គឺជាការប្រគល់វត្ថុផ្ញើទៅឱ្យអ្នកផ្ញើ ក្នុងករណីដែលទំនាក់ទំនងគតិយុត្តនៃការផ្ញើនោះមោឃៈ ដោយសារការភាន់ច្រឡំ ឬ ករណីដែលមូលហេតុនៃផ្ញើរលត់ក្រោយការបង្កើតទំនាក់ទំនងគតិយុត្តនៃផ្ញើនោះ ។ តាមរយៈការប្រគល់វិញនេះ ទំនាក់ទំនងគតិយុត្តនៃការផ្ញើ នឹងត្រូវបានបញ្ចប់ ដោយមិនបានសម្រេចគោលបំណងនៃការផ្ញើ ។ ការប្រគល់វិញ អនុញ្ញាតឱ្យធ្វើទៅបានតែក្នុងករណីដែលការផ្ញើនោះមោឃៈតាំងតែពីដំបូង ដោយសារមានការភាន់ច្រឡំ និង ករណីដែលមូលហេតុនៃការផ្ញើបានរលត់ ក្រោយការបង្កើតទំនាក់ទំនងគតិយុត្តនៃការផ្ញើប៉ុណ្ណោះ (មាត្រា ១៤) ។

២. ប្រការនេះចែងថា ជនដែលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវបញ្ជាក់ពីសិទ្ធិទាមទារឱ្យប្រគល់ឱ្យនោះ ដោយអនុលោមតាមបញ្ញត្តិនៃប្រកាសនេះ ។

កថាខណ្ឌទី ១ ប្រការ ១៥ នៃប្រកាសនេះចែងថា ជនដែលទាមទារឱ្យប្រគល់ឱ្យ ឬ ទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ត្រូវដាក់លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ តាមទម្រង់លេខ ១៣ ឬ លេខ ១៤ នៃឧបសម្ព័ន្ធ ហើយប្រការ ១៦ កថាខណ្ឌទី ១ ចែងថា ត្រូវភ្ជាប់នូវឯកសារដែលបញ្ជាក់ថា អ្នកទាមទារ មានសិទ្ធិទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ ជាមួយនឹងលិខិតពាក្យសុំទាមទារឱ្យប្រគល់ ។ ហេតុដូច្នេះ ការបញ្ជាក់ដែលបានកំណត់នៅក្នុងប្រការនេះ នឹងត្រូវធ្វើឡើងតាមរយៈលិខិតពាក្យសុំទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ព្រមជាមួយនឹងឯកសារភ្ជាប់នឹងលិខិតពាក្យសុំនោះ ។

**ប្រការ ១៤**.- ការប្រគល់វិញនូវវត្ថុផ្ញើ

អ្នកផ្ញើអាចទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ដោយអនុលោមតាមបញ្ញត្តិនៃប្រកាសនេះបាន តែក្នុងករណីដែលអ្នកផ្ញើនោះបញ្ជាក់នូវចំណុចណាមួយ ក្នុងចំណោមចំណុចខាងក្រោម :

ក-ការផ្ញើត្រូវបានធ្វើដោយការភាន់ច្រឡំ ។

ខ-មូលហេតុនៃការផ្ញើបានរលត់ ។

(កំណត់)

១. ចំពោះអត្ថន័យនៃការប្រគល់វិញនូវវត្ថុផ្ញើ សូមមើលកំណត់ទី ១ នៃប្រការ ១៣ ។

២. ដោយព្រោះគោលបំណងនៃការផ្ញើ គឺជាការផ្ទុកផ្ដាក់ដល់ស្ថាប័នរដ្ឋនូវការថែរក្សាគ្រប់គ្រងនូវវត្ថុផ្ញើ ដោយផ្អែកលើបញ្ញត្តិច្បាប់ ដើម្បីសម្រេចនូវគោលបំណងកំណត់មួយតាមផ្លូវច្បាប់ អ្នកផ្ញើមិនអាចទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ តាមទំនើងចិត្តខ្លួនបានទេ ។ ការប្រគល់វិញនូវវត្ថុផ្ញើនោះអាចអនុញ្ញាតឱ្យធ្វើទៅបានតែក្នុងករណីដែលការផ្ញើនោះមោឃៈពីដំបូងមក ហើយមិនមានភាពចាំបាច់រក្សានូវទំនាក់ទំនងគតិយុត្តនៃការផ្ញើនោះ ឬ ករណីដែលភាពចាំបាច់ រក្សាទុកនូវការផ្ញើនោះលែងមានក្រោយពេលបានផ្ញើ ។

ប្រការនេះចែងអំពីល័ក្ខខ័ណ្ឌដើម្បីប្រគល់វិញនូវវត្ថុផ្ញើ ។ (១) ចំពោះករណីដែលការផ្ញើមោឃៈតាំងពីដំបូង ប្រការនេះចែងអំពីករណីដែលការផ្ញើត្រូវបានធ្វើឡើងដោយភាន់ច្រឡំ ។ (២) រីឯចំពោះករណីដែលភាពចាំបាច់រក្សាទុកនូវការផ្ញើ លែងមាន ដោយសារតែការផ្លាស់ប្តូរស្ថានភាព ក្រោយពេលបានផ្ញើវិញ ប្រការនេះចែងអំពីករណីដែលមូលហេតុនៃការផ្ញើបានរលត់ ។

ឧទាហរណ៍ចំពោះល័ក្ខខ័ណ្ឌទី ១ ខាងលើ គឺមានដូចជា ចាប់តាំងពីពេលដែលដាក់ពាក្យសុំផ្ញើ អ្នកដាក់ពាក្យសុំផ្ញើតែងតែគិតដោយភាន់ច្រឡំថា មានមូលហេតុដែលត្រូវធ្វើការផ្ញើ ទោះបីជាគ្មានមូលហេតុនោះក៏ដោយ ។

ដោយឡែក ឧទាហរណ៍ចំពោះល័ក្ខខ័ណ្ឌទី ២ វិញ គឺមានដូចជាករណីដែលការផ្ញើត្រូវបានធ្វើឡើងដើម្បីគោលបំណងដាក់ប្រាតិភោគ ប៉ុន្តែ ក្រោយមក មានភាពស្ថាពរថា សិទ្ធិលើបំណុលដែលត្រូវបានធានាដោយប្រាតិភោគនោះមិនកើតឡើងទេ ឬ ករណីដែលអ្នកផ្ញើ ធ្វើការផ្ញើថ្មីដើម្បីប្តូរប្រាតិភោគ (ប្រការ ៩) ហើយទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើពីមុន ។

ការទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ត្រូវធ្វើដោយអ្នកផ្ញើ ឬ ដោយប្រតិសិទ្ធិរបស់អ្នកនោះ ។ បុគ្គលដែលទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ត្រូវបញ្ជាក់អំពីហេតុណាមួយក្នុងចំណោមហេតុដូចមានកំណត់ខាងលើនេះ ។

៣. កថាខណ្ឌទី ១ ប្រការ ១៥ នៃប្រកាសនេះចែងថា ជនដែលទាមទារឱ្យប្រគល់ឱ្យ ឬ ទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ត្រូវដាក់លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ តាមទម្រង់លេខ ១៣ ឬ លេខ ១៤ នៃឧបសម្ព័ន្ធ ហើយប្រការ ១៦ កថាខណ្ឌទី ១ ចែងថា ត្រូវភ្ជាប់នូវឯកសារដែលបញ្ជាក់ថា អ្នកទាមទារ មានសិទ្ធិទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ ជាមួយនឹងលិខិតទាមទារឱ្យប្រគល់ ។ ហេតុដូច្នេះ ការបញ្ជាក់ដែលបានកំណត់នៅក្នុងប្រការនេះ នឹងត្រូវធ្វើឡើងតាមរយៈលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ព្រមជាមួយនឹងឯកសារភ្ជាប់នឹងលិខិតទាមទារនោះ ។

**ប្រការ ១៥.**- ការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ

១-ជនដែលទាមទារឱ្យប្រគល់ឱ្យ ឬ ឱ្យប្រគល់វិញនូវវត្ថុផ្ញើ ត្រូវដាក់ទៅក្រឡាបញ្ជី នូវលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ តាមទម្រង់លេខ ១៣ ឬ លេខ ១៤ នៃឧបសម្ព័ន្ធ ទៅតាមប្រភេទនៃវត្ថុផ្ញើ ។

២-លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវសរសេរនូវចំណុចខាងក្រោមនេះ ហើយត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកទាមទារ ឬ អ្នកតំណាងនីតិបុគ្គល (ក្នុងករណីដែលអ្នកទាមទារជានីតិបុគ្គល) ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិរបស់អ្នកទាមទារ :

ក-លេខបញ្ញើ ។

ខ-ចំនួននៃប្រាក់ផ្ញើដែលទាមទារឱ្យប្រគល់ ឬ ប្រសិនបើទាមទារឱ្យប្រគល់នូវឧបករណ៍អាចជួញដូរបាន គឺ ឈ្មោះ ចំនួនទឹកប្រាក់សរុប ចំនួនទឹកប្រាក់មួយសន្លឹក (ចំពោះឧបករណ៍អាចជួញដូរបានដែលគ្មានសរសេរចំនួនទឹកប្រាក់ទេ ត្រូវសរសេរការណ៍នោះ) លេខស៊េរី លេខរៀង ចំនួនសន្លឹក និង ចំណុចផ្សេងទៀតដែល

សម្គាល់អត្តសញ្ញាណនៃឧបករណ៍នោះ ។

គ-មូលហេតុនៃការទាមទារឱ្យប្រគល់ ។

ឃ-ប្រភេទនៃការទាមទារឱ្យប្រគល់ (ជាការទាមទារឱ្យប្រគល់ឱ្យ ឬ ជាការទាមទារឱ្យប្រគល់វិញ) ។

ង-ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និង អាសយដ្ឋានរបស់អ្នកទាមទារ ហើយប្រសិនបើអ្នកទាមទារជានីតិបុគ្គល គឺ នាមករណ៍ ទីតាំងនៃទីស្នាក់ការជាចម្បង និង ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គលនោះ ។

ច-ប្រសិនបើអ្នកទាមទារជាអ្នកទទួលបន្តសិទ្ធិ (ប្រតិសិទ្ធិ) របស់អ្នកផ្ញើ ឬ អ្នកមានសិទ្ធិទទួលពីការផ្ញើ ត្រូវសរសេរបញ្ជាក់អំពីការណ៍នោះ ។

ឆ-ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិជាអ្នកទាមទារឱ្យប្រគល់ គឺ ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងនោះ ។

ជ-ឈ្មោះតុលាការដែលត្រូវបានទាមទារឱ្យប្រគល់ ។

ឈ-ថ្ងៃ ខែ ឆ្នាំ ទាមទារឱ្យប្រគល់ ។

(កំណត់)

១. ពេលដែលពាក្យសុំផ្ញើត្រូវបានទទួល ហើយទំនាក់ទំនងគតិយុត្តនៃការផ្ញើត្រូវបានបង្កើតឡើង នោះស្ថានភាពដែលតុលាការដែលទទួលការផ្ញើថែរក្សាគ្រប់គ្រងនូវវត្ថុផ្ញើ ។ នីតិវិធីដើម្បីបញ្ចប់ទំនាក់ទំនងគតិយុត្តនៃការផ្ញើនេះ គឺជានីតិវិធីប្រគល់នូវវត្ថុផ្ញើ ។ ការប្រគល់នូវវត្ថុផ្ញើមានពីរប្រភេទ គឺ "ការប្រគល់ឱ្យ" និង "ការប្រគល់វិញ" (ប្រការ ១៣ និង ប្រការ ១៤) ។ ប្រការនេះបញ្ញត្តអំពីនីតិវិធីប្រគល់នូវវត្ថុផ្ញើ ដោយយកអត្ថិភាពនៃការប្រគល់ពីរប្រភេទនេះមកធ្វើជាមូលដ្ឋាន ។

២. កថាខណ្ឌទី ១ នៃប្រការនេះ តម្រូវឱ្យដាក់លិខិតទាមទារឱ្យប្រគល់ នៅពេលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ។ មូលហេតុដែលទាមទារដូច្នេះ គឺ ដូចគ្នាចំពោះមូលហេតុដែលត្រូវដាក់លិខិតពាក្យសុំផ្ញើដែរ គឺដោយផ្អែកលើមូលហេតុថា ការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើត្រូវមានលក្ខណៈជាទម្រង់កំណត់ និង ហេតុផលដែលថា ក្រឡាបញ្ជីដែលទទួលបានការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវតែវិនិច្ឆ័យឱ្យបានឆាប់រហ័សថា ត្រូវទទួល ឬ លើកចោលការទាមទារនោះ ។ កថាខណ្ឌទី ១ នៃប្រការនេះមានចែងថា ជនដែលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវដាក់លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ទៅក្រឡាបញ្ជី តាមទម្រង់លេខ ១៣ ឬ លេខ ១៤ ។ ការទាមទារទាំងឡាយ

ណាដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរ (ទាមទារដោយផ្ទាល់មាត់) ឬ មិនធ្វើតាមទម្រង់លេខ ១៣ ឬ លេខ ១៤ គឺខុសច្បាប់ ។

ទម្រង់នៃលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ដែលត្រូវប្រើប្រាស់ អាស្រ័យទៅតាមប្រភេទនៃវត្ថុផ្ញើ គឺមានដូចខាងក្រោម :

ទម្រង់លេខ ១៣ : លិខិតទាមទារឱ្យប្រគល់នូវប្រាក់ផ្ញើ

ទម្រង់លេខ ១៤ : លិខិតទាមទារឱ្យប្រគល់នូវឧបករណ៍អាចជួញដូរបានដែលបានផ្ញើ ។

៣. កថាខណ្ឌទី ២ នៃប្រការនេះ ចែងអំពីចំណុចដែលត្រូវសរសេរក្នុងលិខិតទាមទារ ។ ទម្រង់លេខ ១៣ និង លេខ ១៤ មានទុកកន្លែងទំនេរសម្រាប់សរសេរចំណុចទាំងនេះ ហើយការទាមទារនោះ នឹងអាចបំពេញបាន ប្រសិនបើទម្រង់លិខិតទាមទារត្រូវបានជ្រើសរើសត្រឹមត្រូវតាមប្រភេទនៃការទាមទារ ហើយកន្លែងទំនេរនោះនឹងត្រូវបានបំពេញអស់ ។

**ប្រការ ១៦**.- ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ជាអាទិ៍

១-អ្នកដែលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវភ្ជាប់ជាមួយលិខិតទាមទារឱ្យប្រគល់ នូវឯកសារដែលបញ្ជាក់ថា ខ្លួនមានសិទ្ធិទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ ។ ក្នុងករណីនេះ អ្នកដែលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវបង្ហាញលិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់សាមីខ្លួនដែលមានបិទរូបថត និង ត្រូវភ្ជាប់ឯកសារចម្លងនៃលិខិតនោះជាមួយលិខិតទាមទារឱ្យប្រគល់ ។

២-ប្រសិនបើនីតិបុគ្គលទាមទារឱ្យប្រគល់ នីតិបុគ្គលនោះត្រូវភ្ជាប់ជាមួយនឹងលិខិតទាមទារឱ្យប្រគល់ នូវលិខិតបញ្ជាក់លក្ខណសម្បត្តិរបស់អ្នកតំណាងរបស់នីតិបុគ្គលនោះដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេល ៣ ខែ គិតមកត្រឹមថ្ងៃទាមទារឱ្យប្រគល់ ។ ក្នុងករណីនេះ អ្នកតំណាងរបស់នីតិបុគ្គលនោះ ត្រូវបង្ហាញលិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនដែលមានបិទរូបថត និង ត្រូវភ្ជាប់ឯកសារចម្លងនៃលិខិតនោះជាមួយលិខិតទាមទារឱ្យប្រគល់ ។

៣-ប្រសិនបើការទាមទារឱ្យប្រគល់ ត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អ្នកតំណាងនោះត្រូវភ្ជាប់ជាមួយនឹង

លិខិតទាមទារឱ្យប្រគល់ នូវលិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងនោះ ។ ក្នុងករណីនេះ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិនោះ ត្រូវបង្ហាញលិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកតំណាងដែលមានបិទរូបថត និង លិខិតផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់សិទ្ធិ និង ត្រូវភ្ជាប់ឯកសារចម្លងនៃលិខិតទាំងពីរនោះជាមួយលិខិតទាមទារឱ្យប្រគល់ ។

(កំណត់)

១. នៅពេលដែលទំនាក់ទំនងគតិយុត្តនៃការផ្ញើត្រូវបានបង្កើតឡើង អ្នកផ្ញើ និង អ្នកមានសិទ្ធិទទួលពីការផ្ញើ ដែលជាភាគីម្ខាងទៀតនៃអ្នកផ្ញើ ធ្វើលទ្ធកម្មនូវសិទ្ធិទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ក្រោមល័ក្ខខ័ណ្ឌកំណត់មួយចំនួន ។ ដោយហេតុថា សិទ្ធិទាមទារឱ្យប្រគល់នូវវត្ថុផ្ញើដែលអ្នកផ្ញើ និង អ្នកមានសិទ្ធិទទួលពីការផ្ញើ ធ្វើលទ្ធកម្ម ដោយការបង្កើតទំនាក់ទំនងគតិយុត្តនៃការផ្ញើ គឺជាសិទ្ធិអរូបិយ ហើយ ដើម្បីអនុវត្តនូវសិទ្ធិនេះ ត្រូវស្របទៅនឹងល័ក្ខខ័ណ្ឌមួយចំនួនដើម្បីអនុវត្តសិទ្ធិនោះជាក់ស្តែង និង ចាំបាច់ត្រូវមានស្ថានភាពអាចអនុវត្តសិទ្ធិនោះបាន ។ម្យ៉ាងទៀត ក្នុងករណីដែលប្រតិសិទ្ធិ (អ្នកទទួលបន្តនូវសិទ្ធិ) របស់អ្នកមានសិទ្ធិទទួលពីការផ្ញើ ឬ របស់អ្នកផ្ញើ ទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ ចាំបាច់ត្រូវបញ្ជាក់ផងដែរថា អ្នកនោះពិតជាទទួលបន្តនូវសិទ្ធិនោះដោយមានសុពលភាព ។ ហេតុដូច្នេះ ដោយយកភាពចាំបាច់ក្នុងការបញ្ជាក់អំពីសិទ្ធិទទួលការប្រគល់ឱ្យ ឬ ប្រគល់វិញ ដោយអ្នកដែលទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ មកធ្វើជាមូលដ្ឋាន កថាខណ្ឌទី ១ នៃប្រការនេះចែងថា បុគ្គលដែលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវភ្ជាប់មកជាមួយនឹងលិខិតទាមទារ នូវឯកសារដែលបញ្ជាក់ថាខ្លួនមានសិទ្ធិទទួលការប្រគល់នោះ ។

ក្នុងករណីដែលនីតិបុគ្គលទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ អ្នកតំណាងនីតិបុគ្គលនោះត្រូវតែមានសិទ្ធិតំណាងឱ្យនីតិបុគ្គលនោះ រីឯ ក្នុងករណីដែលការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អ្នកតំណាងចាំបាច់ត្រូវមានសិទ្ធិតំណាងឱ្យម្ចាស់សិទ្ធិ ។ ហេតុនេះហើយបានជាកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃប្រការនេះចែងថា លិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីលក្ខណសម្បត្តិនៃអ្នកតំណាងរបស់នីតិបុគ្គល ឬ អំពីសិទ្ធិអំណាចរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ ។ គោលគំនិតនៃកថាខណ្ឌទាំងពីរនេះ គឺដូចគ្នានឹងប្រការ ៧ ដែរ ។

២. ដូចដែលបានពន្យល់ក្នុងកំណត់លេខ ១ ខាងលើនេះ ដើម្បីទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ ល័ក្ខខ័ណ្ឌដើម្បីអនុវត្តសិទ្ធិទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ ត្រូវបានបំពេញ និង ចាំបាច់ត្រូវមានស្ថានភាពអាចអនុវត្តសិទ្ធិនោះបាន ។ មានន័យថា ដើម្បីទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ សិទ្ធិជាសារធាតុចំពោះវត្ថុផ្ញើ របស់អ្នកមានសិទ្ធិទទួលពីការផ្ញើ

ត្រូវបានកំណត់ជាស្ថាពរ ។ ដោយសារមូលហេតុនេះ ឯកសារដែលបញ្ជាក់អំពីសិទ្ធិនោះ ត្រូវតែដាក់ភ្ជាប់ជាមួយលិខិតទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ (កថាខណ្ឌទី ១ នៃប្រការនេះ) ។ ឧទាហរណ៍ ក្នុងករណីដែលផ្ញើដើម្បីជាការផ្តល់ប្រាតិភោគតាមផ្លូវតុលាការ (ការផ្ញើប្រាតិភោគ) អ្នកមានសិទ្ធិទទួលពីការផ្ញើដែលមានសិទ្ធិលើប្រាតិភោគនោះ ត្រូវបញ្ជាក់ថា ខ្លួនមានសិទ្ធិលើបំណុលដែលត្រូវបានធានាដោយប្រាតិភោគដែលត្រូវបានផ្តល់ដោយការផ្ញើនោះ (សិទ្ធិទាមទារឱ្យបង្វិលសងវិញនូវប្រាក់ប្រដាប់ក្តី ក្នុងករណីជាប្រាតិភោគសម្រាប់ធានាប្រាក់ប្រដាប់ក្តី ឬ សិទ្ធិទាមទារសំណងការខូចខាត ក្នុងករណីជាប្រាតិភោគសម្រាប់ធានាសំណងការខូចខាត) ។

ចំពោះប្រាតិភោគធានាសំណងការខូចខាត លិខិតដែលបញ្ជាក់អំពីសិទ្ធិទទួលបាននូវការប្រគល់ឱ្យនូវវត្ថុផ្ញើ គឺមានដូចជាសាលក្រម ឬ សាលដីកាស្ថាពរដែលទទួលស្គាល់ថា អ្នកផ្ញើមានកាតព្វកិច្ចបង់ប្រាក់ទៅអ្នកមានសិទ្ធិទទួលពីការផ្ញើ ចំពោះសិទ្ធិទាមទារសំណងនៃការខូចខាតដែលជាសិទ្ធិលើបំណុលដែលត្រូវបានធានា ។

ការប្រគល់ឱ្យនូវវត្ថុផ្ញើ ត្រូវធ្វើឡើងទៅតាមការទាមទាររបស់អ្នកមានសិទ្ធិទទួលពីការផ្ញើ ឬ ប្រតិសិទ្ធិរបស់អ្នកនោះ ។ ក្នុងករណីដែលប្រតិសិទ្ធិរបស់អ្នកមានសិទ្ធិទទួលពីការផ្ញើនោះ (សន្តតិជន ឬ អនុប្បទានិកដែលទទួលបាននូវអនុប្បទានសិទ្ធិលើបំណុលចំពោះសិទ្ធិទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ ពីអ្នកមានសិទ្ធិទទួលពីការផ្ញើ ជាអាទិ៍) ធ្វើការទាមទារឱ្យប្រគល់ឱ្យនូវវត្ថុផ្ញើ ប្រតិសិទ្ធិនោះ ចាំបាច់ត្រូវភ្ជាប់នូវលិខិតបញ្ជាក់អំពីអង្គហេតុស្តីពីការទទួលបន្ត ជាលិខិតទាមទារ ។

៣. ការប្រគល់វិញនូវវត្ថុផ្ញើ អាចអនុញ្ញាតឱ្យធ្វើទៅបានតែក្នុងករណីដែល ① ការផ្ញើត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ឬ ②មូលហេតុនៃការផ្ញើបានរលត់ ។ ហេតុដូច្នេះ អ្នកទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ត្រូវភ្ជាប់នូវលិខិតដែលបញ្ជាក់ថា ល័ក្ខខ័ណ្ឌសម្រាប់ការប្រគល់វិញនូវវត្ថុផ្ញើ ត្រូវបានបំពេញ ជាមួយនឹងលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ (កថាខណ្ឌទី ១ នៃប្រការនេះ) ។ លិខិតដើម្បីបញ្ជាក់ចំពោះករណី① គឺមានដូចជា សាលក្រម ឬ សាលដីកាស្ថាពរដែលបញ្ជាក់អំពីមោឃភាពនៃការផ្ញើអសុពល ដោយសារការភាន់ច្រឡំ រីឯលិខិតបញ្ជាក់ចំពោះករណី②មានដូចជាដីកាសម្រេចលុបចោលប្រាតិភោគរបស់តុលាការ ជាដើម ។

ប្រសិនបើប្រតិសិទ្ធិរបស់អ្នកផ្ញើ (សន្តតិជន ឬ អនុប្បទានិកដែលទទួលបាននូវអនុប្បទានសិទ្ធិលើបំណុលចំពោះសិទ្ធិទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ពីអ្នកផ្ញើ ជាអាទិ៍) ធ្វើការទាមទារឱ្យប្រគល់វិញនូវវត្ថុផ្ញើ ប្រតិសិទ្ធិនោះ ត្រូវភ្ជាប់នូវលិខិតបញ្ជាក់អំពីអង្គហេតុស្តីពីការទទួលបន្តនោះ ជាមួយលិខិតទាមទារដែរ ។

៤. ដោយសារការពិនិត្យដែលធ្វើឡើងដោយក្រឡាបញ្ជីដែលទទួលបន្ទុកកិច្ចការផ្ញើ គឺជាការពិនិត្យឯកសារ កថាខណ្ឌទី ១ នៃប្រការនេះ កំណត់ថា ជនដែលទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ ត្រូវបញ្ជាក់ថាខ្លួនមានសិទ្ធិទាមទារឱ្យប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើ ដោយឯកសារភ្ជាប់ជាមួយលិខិតិទាមទារ ។ ដូច្នេះ មធ្យោបាយផ្សេងទៀតដូចជាការសាកសួរសាក្សី ឬ ភាគី ឬ ការសួរជនពាក់ព័ន្ធ ក្រៅពីការពិនិត្យឯកសារ គឺមិន

អាចប្រើប្រាស់ដើម្បីបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិនោះបានឡើយ ។ ចំពោះចំណុចនេះ ត្រូវបកស្រាយថា ត្រូវអនុវត្ត ដូចគ្នា ចំពោះករណីដែលតុលាការធ្វើការវិនិច្ឆ័យលើពាក្យសុំតវ៉ាចំពោះការចាត់ចែងរបស់ក្រឡាបញ្ជី និង បណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ានោះដែរ (ប្រសិនបើមិនបកស្រាយបែបនេះទេ ការចាត់ចែងរបស់ក្រឡាបញ្ជីអាចត្រូវបានលុបចោល ដោយធនធានភស្តុតាងផ្សេងៗដែលមិនអាចត្រូវបានយកមកពិចារណា នៅពេលដែលក្រឡាបញ្ជីបានធ្វើការចាត់ចែងនោះ ។ ការធ្វើបែបនេះគឺមិនមានភាពសមរម្យទេ) ។

៥. ចំពោះការភ្ជាប់នូវលិខិតបញ្ជាក់លក្ខណសម្បត្តិរបស់អ្នកតំណាងរបស់នីតិបុគ្គល (កថាខណ្ឌទី ២) និង លិខិតបញ្ជាក់សិទ្ធិអំណាចរបស់អ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិ (កថាខណ្ឌទី ៣) វិញ សូមមើលកំណត់នៃប្រការ ៧ ។

## ប្រការ ១៧.- ការអនុញ្ញាតឱ្យប្រគល់នូវវត្ថុផ្ញើ

ប្រសិនបើយល់ឃើញថា ការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើមានមូលហេតុត្រឹមត្រូវ ក្រឡាបញ្ជីត្រូវសរសេរអំពីការណ៍ដែលអនុញ្ញាតឱ្យប្រគល់ នៅលើលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ត្រូវចុះហត្ថលេខាលើលិខិតនោះ ត្រូវប្រគល់វត្ថុផ្ញើទៅអ្នកទាមទារ ហើយត្រូវឱ្យអ្នកទាមទារបញ្ជាក់ពីការបានទទួលវត្ថុផ្ញើនោះ ។

(កំណត់)

ប្រសិនបើក្រឡាបញ្ជីបានទទួលការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ក្រឡាបញ្ជីត្រូវសម្រេចថា ត្រូវអនុញ្ញាត ឬ លើកចោលការទាមទារ ។ ប្រការនេះចែងថា ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ការទាមទារនោះបានបំពេញល័ក្ខខ័ណ្ឌត្រឹមត្រូវ ហើយត្រូវអនុញ្ញាត នោះក្រឡាបញ្ជីត្រូវធ្វើការចាត់ចែងអនុញ្ញាតឱ្យប្រគល់ ។ ប្រការនេះក៏បានបញ្ញត្តផងដែរថា ក្រឡាបញ្ជីត្រូវសរសេរអំពីការណ៍ដែលអនុញ្ញាតឱ្យប្រគល់ នៅក្នុងលិខិតទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ហើយត្រូវចុះហត្ថលេខាលើលិខិតទាមទារនោះ ព្រមទាំងប្រគល់វត្ថុផ្ញើទៅអ្នកទាមទារ ហើយត្រូវឱ្យអ្នកទាមទារនោះ ធ្វើការបញ្ជាក់ពីការបានទទួលវត្ថុផ្ញើ ។ ទំនាក់ទំនងគតិយុត្តនៃការផ្ញើត្រូវរលត់ នៅពេលដែលវត្ថុផ្ញើត្រូវបានប្រគល់ស្រេច ។

## ប្រការ ១៨.- ការសរសេរនៅក្នុងលិខិតពាក្យសុំសម្រាប់តុលាការ ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើ

ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើ ក្រឡាបញ្ជីត្រូវសរសេរនៅក្នុងលិខិតពាក្យសុំ

សម្រាប់តុលាការ នូវថ្ងៃ ខែ ឆ្នាំ ប្រគល់ ប្រភេទនៃការប្រគល់ (ជាការប្រគល់ឱ្យ ឬ ជាការប្រគល់វិញ) ចំនួនប្រគល់ និង ចំនួនសេសសល់ ។ ប៉ុន្តែ ក្នុងករណីដែលប្រគល់នូវវត្ថុផ្ញើទាំងស្រុង ក្រឡាបញ្ជីអាចសរសេរនូវការណ៍ដែលប្រគល់ឱ្យ ឬ ប្រគល់វិញនូវវត្ថុផ្ញើទាំងស្រុង ជំនួសថ្ងៃ ខែ ឆ្នាំ ប្រគល់ ប្រភេទនៃការប្រគល់ (ជាការប្រគល់ឱ្យ ឬ ការប្រគល់វិញ) ចំនួនប្រគល់ និង ចំនួនសេសសល់បាន ។

(កំណត់)

សូមមើលមាត្រា ៦២ កថាខណ្ឌទី ១ នៃបទប្បញ្ញត្តិស្តីពីការចាត់ចែងកិច្ចការតម្កល់ នៃប្រទេសជប៉ុន ។

**ប្រការ ១៩.-** ការលើកចោលនូវការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ

ប្រសិនបើយល់ឃើញថា ការទាមទារឱ្យប្រគល់ពុំមានមូលហេតុត្រឹមត្រូវ ក្រឡាបញ្ជីត្រូវធ្វើលិខិតលើកចោលការទាមទារនោះ ហើយប្រគល់លិខិតនោះឱ្យអ្នកទាមទារ ។

(កំណត់)

ប្រការនេះចែងអំពីការលើកចោលនូវការទាមទារឱ្យប្រគល់នូវវត្ថុផ្ញើ ។ ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ការទាមទារឱ្យប្រគល់វត្ថុផ្ញើនោះពុំមានមូលហេតុត្រឹមត្រូវ ដោយព្រោះមិនបានបំពេញល័ក្ខខ័ណ្ឌទាមទារឱ្យប្រគល់ទេ ក្រឡាបញ្ជីត្រូវធ្វើលិខិតលើកចោលការទាមទារ និង ប្រគល់លិខិតនោះទៅអ្នកទាមទារ ។ ដោយការប្រគល់លិខិតលើកចោល ការជូនដំណឹងអំពីការចាត់ចែងលើកចោល ត្រូវបានធ្វើឡើង ហើយអានុភាពនៃការចាត់ចែងលើកចោល នឹងកើតឡើង ។

# ជំពូកទី ៤
# បញ្ញត្តិផ្សេងៗ

**ប្រការ ២០.**- ការមើលឯកសារដែលទាក់ទងនឹងការផ្ញើ

១-ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការផ្ញើ អាចទាមទារមើលឯកសារដែលទាក់ទងនឹងការផ្ញើនោះបាន ។

២-ជនដែលមានបំណងទាមទារមើលឯកសារ ត្រូវដាក់លិខិតពាក្យសុំ តាមទម្រង់លេខ ១៥ នៃឧបសម្ព័ន្ធ ។

(កំណត់)

ប្រការនេះចែងស្តីពីការមើលឯកសារដែលទាក់ទងនឹងការផ្ញើ ហើយកថាខណ្ឌទី ១ កំណត់ថា ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការផ្ញើ អាចទាមទារមើលឯកសារដែលទាក់ទងនឹងការផ្ញើបាន ។

ចំពោះលិខិតពាក្យសុំ ដើម្បីអនុវត្តដោយងាយស្រួល កថាខណ្ឌទី ២ តម្រូវឱ្យជនដែលមានបំណងទាមទារមើលឯកសារ ដាក់លិខិតពាក្យសុំ តាមទម្រង់លេខ ១៥ នៃឧបសម្ព័ន្ធ ។

**ប្រការ ២១.**- ការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើ

១-ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការផ្ញើ អាចទាមទារឱ្យធ្វើការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើនោះបាន ។

២-ជនដែលមានបំណងទាមទារឱ្យធ្វើការបញ្ជាក់ ត្រូវដាក់លិខិតពាក្យសុំ តាមទម្រង់លេខ ១៦ នៃឧបសម្ព័ន្ធ ។

(កំណត់)

ប្រការនេះចែងស្តីពីការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើ ហើយកថាខណ្ឌទី ១ កំណត់ថា ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការផ្ញើ អាចទាមទារឱ្យធ្វើការបញ្ជាក់អំពីចំណុចដែលទាក់ទងនឹងការផ្ញើបាន ។

ចំពោះលិខិតពាក្យសុំ ដើម្បីអនុវត្តដោយងាយស្រួល កថាខណ្ឌទី ២ តម្រូវឱ្យជនដែលមានបំណងទាមទារឱ្យធ្វើការបញ្ជាក់ ដាក់លិខិតពាក្យសុំ តាមទម្រង់លេខ ១៦ នៃឧបសម្ព័ន្ធ ។

# ជំពូកទី ៥
# អវសានប្បញ្ញត្តិ

**ប្រការ ២២.**- កាលបរិច្ឆេទនៃការអនុវត្ត

ប្រកាសនេះត្រូវអនុវត្ត ១ (មួយ) ខែ ក្រោយពេលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចុះហត្ថលេខាលើប្រកាសនេះ ។

(កំណត់)

ប្រការនេះកំណត់អំពីកាលបរិច្ឆេទនៃការអនុវត្តប្រកាសនេះ ។

ដោយហេតុថា នៅមុនកាលបរិច្ឆេទនៃការអនុវត្តប្រកាសនេះ ពុំមានប្រព័ន្ធផ្ញើនៅតុលាការទេ មិនចាំបាច់អនុវត្តបញ្ញត្តិនៃច្បាប់ពាក់ព័ន្ធនឹងប្រព័ន្ធផ្ញើចាស់ បន្ទាប់ពីការអនុវត្តប្រកាសនេះ ហើយមិនចាំបាច់បង្កើតនូវបញ្ញត្តិពិសេសដែលចែងអំពីទំនាក់ទំនងនៃការអនុវត្ត រវាងប្រកាសនេះ និង ច្បាប់ឬបទដ្ឋានផ្សេងដែលពាក់ព័ន្ធ នៅជុំវិញកាលបរិច្ឆេទនៃការអនុវត្តប្រកាសនេះទេ ។ ដូច្នេះ ប្រកាសនេះមិនមានបញ្ញត្តិចំពោះវិធានការអន្តរកាលទេ ។

ទម្រង់លេខ ១ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

ភេទ :

ថ្ងៃខែឆ្នាំកំណើត :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( អាសយដ្ឋាន) :

( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍

តុលាការ :

សំណុំរឿងលេខ :

ភាគី :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ

☐ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី
☐ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
☐ ៣. ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
☐ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ
☐ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ
☐ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន
☐ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន
☐ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន .
☐ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន
☐១០. ប្រាក់លុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន
☐១១. ( )

(សូមគូស ☑ នៅមុខលេខសមស្រប)

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :
________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល) ( ហាមកែ ឬ កោសលុប) | | | | | | | | | | | | | |
| សរសេរជាអក្សរ | | | | | | | | | | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ។

បានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ២ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្តោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្តីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍

តុលាការ :

សំណុំរឿងលេខ :

ភាគី :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

ភេទ :

ថ្ងៃខែឆ្នាំកំណើត :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( អាសយដ្ឋាន) :

( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ

☐ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្តី

☐ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន

☐ ៣. ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន

☐ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ

☐ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ

☐ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន

☐ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្តោះអាសន្ន

☐ ៨. ប្រាតិភោគសម្រាបការលុបចោលនូវការរឹបអូសជាបណ្តោះអាសន្ន

☐ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្តោះអាសន្ន

☐ ១០. ប្រាក់លុបចោលនូវការរឹបអូសជាបណ្តោះអាសន្ន

☐ ១១. ( )

( សូមគូស ☑ នៅមុខលេខសមស្រប)

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :

________________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

| ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>( ហាមកែ ឬ កោសលុប) | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សរសេរជាអក្សរ | | | | | | | | | | | | |

បានទទួលពាក្យសុំផ្ញើដូចខាងលើនេះ ហើយបានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៣ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

## (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
ភេទ :
ថ្ងៃខែឆ្នាំកំណើត :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :
ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( អាសយដ្ឋាន) :
( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍
តុលាការ :
សំណុំរឿងលេខ :
ភាគី :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ
- ☐ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី
- ☐ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
- ☐ ៣. ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
- ☐ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ
- ☐ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ
- ☐ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន
- ☐ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន
- ☐ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន
- ☐ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន
- ☐ ១០. ប្រាក់លុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន
- ☐ ១១. ( )

(សូមគូស ☑ នៅមុខលេខសមស្រប)

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :
________________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

ឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើ

| ឈ្មោះ | សន្លឹក | ទឹកប្រាក់សរុប | ទឹកប្រាក់មួយសន្លឹក<br>លេខស៊េរី និង លេខរៀង | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ។

បានទទួលឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៤ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)

## (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
ភេទ :
ថ្ងៃខែឆ្នាំកំណើត :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :
ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( អាសយដ្ឋាន) :
( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :
______________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍
តុលាការ :
សំណុំរឿងលេខ :
ភាគី :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ
☐ ១. ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី
☐ ២. ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
☐ ៣.ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន
☐ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ
☐ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ
☐ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន
☐ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន
☐ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន
☐ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន
☐១0. ប្រាក់លុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន
☐១១. ( )

( សូមគូស ☑ នៅមុខលេខសមស្រប)

ផ្សេងៗ

ឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើ

| ឈ្មោះ | សន្លឹក | ទឹកប្រាក់សរុប | ទឹកប្រាក់មួយសន្លឹក<br>លេខស៊េរី និង លេខរៀង | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ហើយបានទទួលឧបករណ៍អាចជួញដូរបានដែលត្រូវបានផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនសន្លឹក និង ទឹកប្រាក់សរុប ដែលប្រគល់ | ចំនួនសន្លឹក និង ទឹកប្រាក់សរុប ដែលនៅសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៥ ( ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

# (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

<table>
<tr><td>ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ</td><td>លេខផ្ញើ : ឆ្នាំ</td></tr>
<tr><td>ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :</td><td rowspan="3">អង្គហេតុដែលជាមូលហេតុនៃការផ្ញើ</td></tr>
<tr><td>ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :<br><br>( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>( អាសយដ្ឋាន) :<br>( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :</td></tr>
<tr><td>ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :</td></tr>
<tr><td>បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>________________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី</td><td>ផ្សេងៗ</td></tr>
<tr><td>ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>( ហាមកែ ឬ កោសលុប)</td><td></td></tr>
<tr><td>សរសេរជាអក្សរ</td><td></td></tr>
</table>

បានទទួលការផ្ញើដូចខាងលើនេះ ។

បានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៦ (ទាក់ទងនឹងប្រការ ៦ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)
# (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)

អ្នកដាក់បញ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
ភេទ :
ថ្ងៃខែឆ្នាំកំណើត :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :
ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :

(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

(អាសយដ្ឋាន) :
(ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :
ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :
អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :
________________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

| ទឹកប្រាក់ផ្ញើ (ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប) | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរសេរជាអក្សរ | | | | | | | | | | | | | |

បានទទួលការផ្ញើដូចខាងលើនេះ ហើយបានទទួលប្រាក់ផ្ញើដូចខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

(កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៧ ( ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

## (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

<table>
<tr><td colspan="5">ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ</td><td colspan="9">លេខផ្ញើ : ឆ្នាំ</td></tr>
<tr><td colspan="5">ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :</td><td colspan="9" rowspan="2">ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍<br>តុលាការ :<br>សំណុំរឿងលេខ :<br>ភាគី :</td></tr>
<tr><td colspan="5" rowspan="2">ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :<br><br>( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>( អាសយដ្ឋាន) :<br>( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :</td></tr>
<tr><td colspan="9" rowspan="2">អង្គហេតុដែលជាមូលហេតុនៃការផ្ញើ<br>☐ ១.ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី<br>☐ ២.ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>☐ ៣.ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន<br>☐ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ<br>☐ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ<br>☐ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន<br>☐ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន<br>☐ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន<br>☐ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន<br>☐ ១០. ប្រាក់លុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន<br>☐ ១១. ( )<br>( សូមគូស ☑ នៅមុខលេខសមស្រប)</td></tr>
<tr><td colspan="5">ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :</td></tr>
<tr><td colspan="5">បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី</td><td colspan="9">ផ្សេងៗ</td></tr>
<tr><td>ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>( ហាមកែ ឬ កោសលុប)</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>សរសេរជាអក្សរ</td><td colspan="13"></td></tr>
</table>

បានទទួលការផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ ( ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី _____ ខែ _______ ឆ្នាំ ______ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បញ្ជាក់ថា បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៨ ( ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)
# (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)
# (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខផ្ញើ : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :

ឈ្មោះតុលាការដែលចាត់ការនីតិវិធីនៃការសម្រេចសេចក្ដីដែលពាក់ព័ន្ធនឹងការផ្ញើ និង លេខសំណុំរឿង ជាអាទិ៍

តុលាការ :

សំណុំរឿងលេខ :

ភាគី :

ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

ភេទ :

ថ្ងៃខែឆ្នាំកំណើត :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( អាសយដ្ឋាន) :

( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

អង្គហេតុដែលជាមូលហេតុនៃការផ្ញើ

☐ ១.ប្រាតិភោគសម្រាប់ប្រាក់ប្រដាប់ក្ដី

☐ ២.ប្រាតិភោគសម្រាប់ការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន

☐ ៣.ប្រាតិភោគដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន

☐ ៤. ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំ

☐ ៥. ប្រាតិភោគសម្រាប់ការលុបចោលនូវការអនុវត្តដោយបង្ខំ

☐ ៦. ប្រាតិភោគសម្រាប់ការរឹបអូសជាបណ្ដោះអាសន្ន

☐ ៧. ប្រាតិភោគសម្រាប់ការចាត់ចែងជាបណ្ដោះអាសន្ន

☐ ៨. ប្រាតិភោគសម្រាប់ការលុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន

☐ ៩. ប្រាតិភោគសម្រាប់ការលុបចោលនូវការចាត់ចែងជាបណ្ដោះអាសន្ន

☐ ១០. ប្រាក់លុបចោលនូវការរឹបអូសជាបណ្ដោះអាសន្ន

☐ ១០. ( )

( សូមគូស ☑ នៅមុខលេខសមស្រប)

ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :

______________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សេងៗ

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>( ហាមកែ ឬ កោសលុប) | | | | | | | | | | | | | |
| សរសេរជាអក្សរ | | | | | | | | | | | | | |

បានទទួលពាក្យសុំផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ ( ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី ____ ខែ ______ ឆ្នាំ ______ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ៩ (ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ)
# (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)
# (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកផ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

| | |
|---|---|
| ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ | លេខផ្ញើ : ឆ្នាំ |
| ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ : | អង្គហេតុដែលជាមូលហេតុនៃការផ្ញើ |
| ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :<br><br>(ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>(អាសយដ្ឋាន) :<br>(ហត្ថលេខា ឬ ស្នាមម្រាមដៃ) : | |
| ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង : | |
| បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>______________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី | ផ្សេងៗ |
| ទឹកប្រាក់ផ្ញើ (ឯកតា : រៀល)<br>(ហាមកែ ឬ កោសលុប) | |
| សរសេរជាអក្សរ | |

បានទទួលការផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ (ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី ____ ខែ ______ ឆ្នាំ ______ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បញ្ជាក់ថា បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

(កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ១០ ( ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ១)

# លិខិតពាក្យសុំផ្ញើ (សម្រាប់តុលាការ)
# (ការផ្ញើប្រាក់ដើម្បីគោលបំណងផ្សេងទៀត)
# (ការបង់តាមវិធីផ្ទេរប្រាក់)

អ្នកដាក់បញ្ញើត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

<table>
<tr><td colspan="5">ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ</td><td colspan="9">លេខផ្ញើ : ឆ្នាំ</td></tr>
<tr><td colspan="5">ឈ្មោះតុលាការដែលត្រូវបានដាក់ពាក្យសុំផ្ញើ :</td><td colspan="9" rowspan="3">អង្គហេតុដែលជាមូលហេតុនៃការផ្ញើ</td></tr>
<tr><td colspan="5">ឈ្មោះ ឬ នាមករណ៍របស់អ្នកផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :<br><br>( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>( អាសយដ្ឋាន) :<br>( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :</td></tr>
<tr><td colspan="5">ឈ្មោះអ្នកមានសិទ្ធិទទួលពីការផ្ញើ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :</td></tr>
<tr><td colspan="5">បញ្ញត្តិច្បាប់ដែលជាមូលដ្ឋាន :<br>________________________ នៃក្រមនីតិវិធីរដ្ឋប្បវេណី</td><td colspan="9">ផ្សេងៗ</td></tr>
<tr><td>ទឹកប្រាក់ផ្ញើ ( ឯកតា : រៀល)<br>( ហាមកែ ឬ កោសលុប)</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>សរសេរជាអក្សរ</td><td colspan="13"></td></tr>
</table>

បានទទួលការផ្ញើដូចខាងលើនេះ ។

សូមផ្ទេរប្រាក់ផ្ញើមកគណនីប្រាក់ផ្ញើរបស់តុលាការនេះ ( ក្រឡាបញ្ជី) រហូតដល់ថ្ងៃទី ____ ខែ ______ ឆ្នាំ ______ ។

ការសម្រេចទទួលការផ្ញើខាងលើនេះ ត្រូវបាត់បង់អានុភាព ប្រសិនបើមិនបានផ្ទេរប្រាក់ផ្ញើរហូត ដល់កាលបរិច្ឆេទខាងលើនេះ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

បានទទួលប្រាក់ផ្ញើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

| ថ្ងៃ ខែ ឆ្នាំ | ចំនួនប្រគល់ | ចំនួនសេសសល់ | ផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |

( កំណត់)

១ ក្នុងករណីដែលធ្វើការផ្ញើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

# លិខិតជូនដំណឹងអំពីការសម្រេចទទួលការផ្ញើ

ការផ្ញើដែលអ្នកបានដាក់ពាក្យសុំ នៅថ្ងៃទី ____ ខែ ______ ឆ្នាំ _____ ត្រូវបានទទួលដោយមាន លេខ : __________ ឆ្នាំ _______ ។

ចំពោះប្រាក់ផ្ញើ សូមផ្ទេរមកគណនីប្រាក់ផ្ញើដែលបានកំណត់ ដោយយកលិខិតស្នើសុំផ្ទេរប្រាក់ដែលភ្ជាប់ជាមួយលិខិតនេះ រហូតដល់ថ្ងៃទី ____ ខែ ______ ឆ្នាំ _____ ។ ប្រសិនបើពុំមានការផ្ទេរប្រាក់ផ្ញើរហូតដល់កាលបរិច្ឆេទនេះ ការសម្រេចទទួលការផ្ញើនេះ ត្រូវបាត់បង់អានុភាព ។

ចំពោះលិខិតពាក្យសុំផ្ញើ (សម្រាប់អ្នកផ្ញើ) នឹងត្រូវប្រគល់ ( ឬ ផ្ញើ) ទៅឱ្យអ្នក ក្រោយពេលទទួលការផ្ទេរប្រាក់ ហេតុដូច្នេះ សូមរក្សាទុកដោយប្រុងប្រយ័ត្ន ។

ថ្ងៃទី ____ ខែ ______ ឆ្នាំ

តុលាការ : ក្រឡាបញ្ជី :

ទម្រង់លេខ ១២ ( ទាក់ទងនឹងប្រការ ១១ កថាខណ្ឌទី ៣)

( ទំព័រទី ១)

# លិខិតស្នើសុំផ្ទេរប្រាក់

<table>
<tr><td>ថ្ងៃស្នើសុំ</td><td colspan="2">ថ្ងៃទី ខែ ឆ្នាំ</td><td colspan="2">ចំនួនទឹកប្រាក់ផ្ទេរ</td><td></td><td>រៀល</td></tr>
<tr><td colspan="2">ស្ថាប័នហិរញ្ញវត្ថុដែលទទួលការផ្ទេរ</td><td colspan="2"></td><td>ចំនួនថ្លៃសេវា</td><td></td><td>រៀល</td></tr>
<tr><td rowspan="2">អ្នកទទួល</td><td>ប្រភេទនៃគណនី</td><td>ចរន្ត</td><td>លេខគណនី</td><td colspan="3"></td></tr>
<tr><td>ឈ្មោះម្ចាស់គណនី</td><td colspan="5"></td></tr>
<tr><td>លេខផ្ញើ</td><td colspan="6">លេខ : ឆ្នាំ</td></tr>
<tr><td rowspan="2">អ្នកស្នើសុំ</td><td>អាសយដ្ឋាន</td><td colspan="5"></td></tr>
<tr><td>ឈ្មោះ ឬ នាមករណ៍</td><td colspan="5"></td></tr>
<tr><td colspan="7">ត្រាទទួល ឬ ត្រាផ្ទេរ របស់ស្ថាប័នហិរញ្ញវត្ថុដែលធ្វើការផ្ទេរ</td></tr>
</table>

# បង្កាន់ដៃទទួលប្រាក់ផ្ទេរ និង តម្លៃសេវា

<table>
<tr><td>ថ្ងៃស្នើសុំ</td><td colspan="2">ថ្ងៃទី ខែ ឆ្នាំ</td><td colspan="2">ចំនួនទឹកប្រាក់ផ្ទេរ</td><td></td><td>រៀល</td></tr>
<tr><td colspan="2">ស្ថាប័នហិរញ្ញវត្ថុដែលទទួលការផ្ទេរ</td><td colspan="2"></td><td>ចំនួនថ្លៃសេវា</td><td></td><td>រៀល</td></tr>
<tr><td rowspan="2">អ្នកទទួល</td><td>ប្រភេទនៃគណនី</td><td>ចរន្ត</td><td colspan="2">លេខគណនី</td><td colspan="2"></td></tr>
<tr><td>ឈ្មោះម្ចាស់គណនី</td><td colspan="5"></td></tr>
<tr><td>លេខផ្ញើ</td><td colspan="6">លេខ : ឆ្នាំ</td></tr>
<tr><td rowspan="2">អ្នកស្នើសុំ</td><td>អាសយដ្ឋាន</td><td colspan="5"></td></tr>
<tr><td>ឈ្មោះ ឬ នាមករណ៍</td><td colspan="5"></td></tr>
<tr><td colspan="7">ត្រាទទួល របស់ស្ថាប័នហិរញ្ញវត្ថុដែលធ្វើការផ្ទេរ</td></tr>
</table>

ទម្រង់លេខ ១៣ ( ទាក់ទងនឹងប្រការ ១៥ កថាខណ្ឌទី ១)

# លិខិតទាមទារឱ្យប្រគល់នូវប្រាក់ផ្ញើ

## (ការផ្ញើប្រាក់ដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកទាមទារត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ

លេខទទួល : ឆ្នាំ

ឈ្មោះតុលាការដែលត្រូវបានទាមទារឱ្យប្រគល់ :

ឈ្មោះ ឬ នាមករណ៍របស់អ្នកទាមទារ :

ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :

ភេទ :

ថ្ងៃខែឆ្នាំកំណើត :

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :

ហត្ថលេខា ឬ ស្នាមម្រាមដៃ[១] :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( អាសយដ្ឋាន) :

( ហត្ថលេខា ឬ ស្នាមម្រាមដៃ) :

មូលហេតុនៃការទាមទារឱ្យប្រគល់

និង ការបញ្ជាក់អំពីការប្រគល់ឱ្យ ឬ ការប្រគល់វិញ

□ការប្រគល់ឱ្យ □១. អនុវត្តសិទ្ធិប្រាតិភោគ

□២. ( )

□ការប្រគល់វិញ □១. ការរលត់នៃមូលហេតុនៃការផ្ញើ

□២. ( )

( សូមគូស ☑ នៅមុខលេខបញ្ជាក់មូលហេតុដែលសមស្រប ។ ក្រៅពីមូលហេតុ "អនុវត្តសិទ្ធិប្រាតិភោគ" ឬ "ការរលត់នៃមូលហេតុនៃការផ្ញើ" សូមសរសេរបញ្ជាក់អំពីមូលហេតុ នៅក្នុងវង់ក្រចកខាងលើនេះ ។

ផ្សេងៗ

| លេខបញ្ញើ | ចំនួនទឹកប្រាក់បញ្ញើ |
|---|---|
| លេខ ឆ្នាំ | |
| លេខ ឆ្នាំ | |
| លេខ ឆ្នាំ | |
| លេខ ឆ្នាំ | |
| ទឹកប្រាក់សរុប | |

បានយល់ព្រមប្រគល់ដូចមានបញ្ជាក់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

បានទទួលប្រាក់ដូចដែលមានបញ្ជាក់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

ឈ្មោះអ្នកទទួល :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( កំណត់)

១ ក្នុងករណីដែលធ្វើការទាមទារដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

ទម្រង់លេខ ១៤ ( ទាក់ទងនឹងប្រការ ១៥ កថាខណ្ឌទី ១)

# លិខិតទាមទារឱ្យប្រគល់នូវឧបករណ៍អាចជួញដូរបានដែលបានផ្ញើ

## (ការផ្ញើឧបករណ៍អាចជួញដូរបានដើម្បីធានាតាមផ្លូវតុលាការ និង ដើម្បីរំដោះពីការរឹបអូសជាបណ្ដោះអាសន្ន)

អ្នកទាមទារត្រូវបំពេញក្នុងប្រអប់ដែលមានបន្ទាត់ក្រាស់ ។

| | |
|---|---|
| ថ្ងៃខែឆ្នាំដាក់ពាក្យសុំ : ថ្ងៃទី ខែ ឆ្នាំ | លេខទទួល : ឆ្នាំ |
| ឈ្មោះតុលាការដែលត្រូវបានទាមទារឱ្យប្រគល់ : | មូលហេតុនៃការទាមទារឱ្យប្រគល់<br>និង ការបញ្ជាក់អំពីការប្រគល់ឱ្យ ឬ ការប្រគល់វិញ<br><br>□ការប្រគល់ឱ្យ □១. អនុវត្តសិទ្ធិប្រាតិភោគ<br>□២. ( )<br><br>□ការប្រគល់វិញ □១. ការរលត់នៃមូលហេតុនៃការផ្ញើ<br>□២. ( )<br><br>( សូមគូស ☑ នៅមុខលេខបញ្ជាក់មូលហេតុដែលសមស្រប ។ ក្រៅពីមូលហេតុ "អនុវត្តសិទ្ធិប្រាតិភោគ" ឬ "ការរលត់នៃមូលហេតុនៃការផ្ញើ" សូមសរសេរបញ្ជាក់អំពីមូលហេតុ នៅក្នុងវង់ក្រចកខាងលើនេះ ។ |
| ឈ្មោះ ឬ នាមករណ៍របស់អ្នកទាមទារ :<br>ឈ្មោះអ្នកតំណាងរបស់នីតិបុគ្គល :<br>ភេទ :<br>ថ្ងៃខែឆ្នាំកំណើត :<br>អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង :<br>ហត្ថលេខា ឬ ស្នាមម្រាមដៃ[1] :<br><br>( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :<br><br>( អាសយដ្ឋាន) :<br>( ហត្ថលេខា ឬ ស្នាមម្រាមដៃ) : | ផ្សេងៗ |

| លេខបញ្ញើ | ឈ្មោះ | សន្លឹក | ទឹកប្រាក់សរុប | ទឹកប្រាក់មួយសន្លឹក<br>លេខសេរី និង លេខរៀង | ផ្សេងៗ |
|---|---|---|---|---|---|
| លេខ ឆ្នាំ | | | | | |
| លេខ ឆ្នាំ | | | | | |
| លេខ ឆ្នាំ | | | | | |
| លេខ ឆ្នាំ | | | | | |
| សរុប | | | | | |

បានយល់ព្រមប្រគល់ដូចមានបញ្ជាក់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

តុលាការ :

ក្រឡាបញ្ជី :

បានទទួលឧបករណ៍អាចជួញដូរបានដែលមានបញ្ជាក់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

ឈ្មោះអ្នកទទួល :

( ឈ្មោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ) :

( កំណត់)

១ ក្នុងករណីដែលធ្វើការទាមទារដោយអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ មិនចាំបាច់មានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់ម្ចាស់សិទ្ធិទេ ។

# លិខិតពាក្យសុំឱ្យមើលឯកសារ

ជូនចំពោះតុលាការ ______________________________

គោលបំណងនៃការមើល :

( ការពាក់ព័ន្ធនឹងផលប្រយោជន៍)

ឯកសារទាក់ទង និង ផ្នែកនៃឯកសារនោះដែលទាមទារឱ្យមើល :

ខ្ញុំស្នើសុំឱ្យមើលឯកសារ ដូចដែលបានរៀបរាប់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

អ្នកដាក់ពាក្យសុំ[១] : □អ្នកផ្ញើ □អ្នកមានសិទ្ធិទទួលពីការផ្ញើ □អ្នកដទៃ

ឈ្មោះ ឬ នាមករណ៍

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង

១ សូមគូស ☑ នៅមុខប្រភេទនៃអ្នកដាក់ពាក្យសុំ ។

ទម្រង់លេខ ១៦ ( ទាក់ទងនឹងប្រការ ២១ កថាខណ្ឌទី ២)

# លិខិតពាក្យសុំឱ្យធ្វើការបញ្ជាក់

ជូនចំពោះតុលាការ ______________________________

គោលបំណងនៃការទាមទារឱ្យធ្វើការបញ្ជាក់ :

( ការពាក់ព័ន្ធនឹងផលប្រយោជន៍)

ចំណុចដែលទាមទារឱ្យធ្វើការបញ្ជាក់ :

ខ្ញុំស្នើសុំឱ្យធ្វើការបញ្ជាក់ ដូចដែលបានរៀបរាប់ខាងលើ ។

ថ្ងៃទី ខែ ឆ្នាំ

អ្នកដាក់ពាក្យសុំ[១] : □អ្នកផ្ញើ □អ្នកមានសិទ្ធិទទួលពីការផ្ញើ □អ្នកដទៃ

ឈ្មោះ ឬ នាមករណ៍

អាសយដ្ឋាន ឬ ទីតាំងនៃទីស្នាក់ការចម្បង

១ សូមគូស ☑ នៅមុខប្រភេទនៃអ្នកដាក់ពាក្យសុំ ។